# តើអ្នកណាផ្លាស់ប្តូរ

# ថ្ងៃសប្ប័ទ

# ទៅ ជាថ្ងៃអាទិត្យ?

ដោយ ប៊ូ ឈុំ

# តើអ្នកណាផ្លាស់ប្តូរ

# ថ្ងៃសប្ប័ទ

# ទៅ ជាថ្ងៃអាទិត្យ?

បទគម្ពីរចម្លង ក្នុងខិត្តប័ណ្ណនេះ
ដកស្រង់ចេញពីគម្ពីរបោះពុម្ព ឆ្នាំ១៩៥៤

«...មានសេចក្ដីចែងទុកមកដូច្នេះ មនុស្សមិនមែនរស់ ដោយសារតែនំបុ័ង...[បាយ]...ប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ៤:៤)

ទំនាក់ទំនង: ប៊ូ ឈុំ
ទូរស័ព្ទលេខ: 016 509 779/ 011 435 441/ 097 990 6244
e-mail:chumbou2020@gmail.com

# តើអ្នកណាផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅជាថ្ងៃអាទិត្យ?

នេះជាការសិក្សាជាបន្តបន្ទាប់ ពីថ្ងៃសប្ប័ទ ក្នុងបទព្រះគម្ពីរ ឥឡូវនេះ នៅពេលយើងចូលទៅជិតចំណុចនេះ ចូរយើងយល់ពីអ្វីមួយដែលមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងអ្វីៗគ្រប់យ៉ាងដែលយើងធ្វើៗ ចូរចាប់ផ្តើមដំបូង ដោយចូលទៅកាន់ គម្ពីរហេព្រើរ ១១: ពីព្រោះនេះជាមូលដ្ឋានដែលត្រូវតែមាននៅក្នុងជីវិតរបស់យើងពល់គ្នា ដែលយើងត្រូវតែជឿព្រះ យើងត្រូវតែជឿព្រះបន្ទូលរបស់ព្រះ យើងត្រូវតែជឿថាទ្រង់ជាព្រះពិត ហើយព្រះទ្រង់មានបន្ទូល ដូចដែលបានសរសេរទុកនៅក្នុងព្រះគម្ពីរ ហេព្រើរ ១១:៦ «តែបើឥតមានមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ» ដោយហេតុនោះហើយបានជាមានមនុស្សជាច្រើន កាលណាគេចូលទៅក្នុងសាសនាឬចូលទៅក្នុងពួកជំនុំ មិនយូរប៉ុន្មានក៏បង្រៀនថាព្រះនៅឯស្ថានសួគ៌យ៉ាងឆ្ងាយ ដោយសារពួកគេមិនផ្តោតលើព្រះនឹងព្រះបន្ទូលរបស់ទ្រង់ ជាចំណុចដ៏សំខាន់ ដែលគេត្រូវធ្វើនៅក្នុងជីវិតរបស់ខ្លួនៗ «...នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ» ឥឡូវនេះ ចូរយើងយល់ការមួយៈ គឺយើងត្រូវ «...គាប់ដល់

ព្រះហឫទ័យព្រះ...» មនុស្សភាគច្រើនចង់ផ្គាប់ចិត្តអ្នកដទៃ ឬផ្គាប់ចិត្តបុរស ឬផ្គាប់ចិត្តស្ត្រី ប៉ុន្តែអ្នកត្រូវតែផ្គាប់ដល់ព្រះហឫទ័យនៃព្រះវិញ។ មនុស្សមិនអាចផ្គាប់ចិត្តដល់អ្នកដទៃបាន ពីព្រោះមនុស្សមិនស្គាល់ចិត្តរបស់មនុស្សទេ មានពេលខ្លះមនុស្ស គេចង់ធ្វើអ្វីៗទៅតាមចិត្តចង់របស់គេ ប៉ុន្តែ ដោយមានសេចក្តីជំនឿ អ្នកអាចធ្វើឲ្យព្រះសព្វព្រះហឫទ័យបាន «៦...ដ្បិតអ្នកណាដែលចូលទៅឯព្រះ... [យើងកំពុងមកឯព្រះ]... នោះត្រូវតែជឿ... [នេះមានន័យថា យើងស្ថិតនៅក្រោមកាតព្វកិច្ចត្រូវជឿ] ...ថាមានព្រះមែន ហើយថាទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់ផង» ដូច្នេះ យើងមានសំណួរ ពីថ្ងៃសប្ប័ទ នឹងថ្ងៃអាទិត្យ តើអ្នកជឿថាថ្ងៃណា ជាថ្ងៃដែលបានតាំងសំរាប់មនុស្សមិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទទេ» (ម៉ាកុស២:២៧) តើអ្នកជឿព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទឬទេ? អ្នកត្រូវតែជឿព្រះវរបិតានឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយយើងនឹងឃើញថា ថ្ងៃសប្ប័ទ គឺជាសេចក្តីសន្យានៃសញ្ញាថ្មី។ យើងនឹងរៀនពីការដ៏គួរឲ្យភ្ញាក់ផ្អើលមួយចំនួន ដែលទាក់ទងនឹងថ្ងៃអាទិត្យ ដោយពួកកាតូលិក នឹងពួកប្រូតេស្តង់។ យើងនឹងរៀន តើអ្នកណាផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅជាថ្ងៃអាទិត្យ?

**ទីមួយ:** ឥឡូវនេះ ចូរយើងពិនិត្យមើលឡើងវិញ ពីព្រះអង្គដែលទ្រង់បង្កើតថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ គម្ពីរយ៉ូហានជំពូកមួយ ១. «កាលពីដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយ

នឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ២. ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក ៣. គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ»

ដូច្នេះ ថ្ងៃសប្ប័ទ ត្រូវបានបង្កើតឡើងដោយព្រះអង្គទ្រង់ដែលក្រោយមកទ្រង់បានយកនិស្ស័យជាមនុស្ស គឺព្រះយេស៊ូវគ្រីស្ទ ដូច្នេះ ទ្រង់ ជាព្រះនៃគម្ពីរសញ្ញាចាស់ ហេតុនេះហើយ ២៧. «...បានជាព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា ថ្ងៃឈប់សំរាក... [ថ្ងៃសប្ប័ទ]... បានតាំងសំរាប់មនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ ២៨. ដូច្នេះ កូនមនុស្ស...[ព្រះយេស៊ូវ]... ជាម្ចាស់នៃថ្ងៃឈប់សំរាកដែរ» (ម៉ាកុស២:២៧-២៨)

**ទីពីរ:** បញ្ញត្តិទីបួនចែងថា «ចូរឲ្យនឹកចាំពីឈប់សំរាក... [ថ្ងៃសប្ប័ទ]... ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើការអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ា ទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់

សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨-១១)

ទីបី: យើងមិនបានរកឃើញថា កិច្ចសន្យាថ្មី ថាថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទសំរាប់តែសាសន៍យូដាតែប៉ុណ្ណោះទេ គ្មានកន្លែងណាក្នុងព្រះគម្ពីរបានចែងនោះទេ។ ព្រះទ្រង់មានបន្ទូលយ៉ាងច្បាស់ថា ថ្ងៃសប្ប័ទជាថ្ងៃបរិសុទ្ធរបស់ទ្រង់ ហើយថ្ងៃបុណ្យបរិសុទ្ធ ទាំងប៉ុន្មាន ក៏ជាថ្ងៃឈប់សំរាក ឬជាថ្ងៃសប្ប័ទរបស់ទ្រង់ដែរ ពីព្រោះព្រះទ្រង់ជាអង្គដែលបង្កើតថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ហើយទ្រង់ក៏ជាម្ចាស់ ត្រួតត្រា នឹងគ្រប់គ្រងលើថ្ងៃបរិសុទ្ធទាំងអស់នោះផង។ ដូច្នេះហើយ ព្រះទ្រង់ជាអង្គដែលកំណត់សេចក្ដីសញ្ញានៃថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទនេះ ទុកជាច្បាប់ នឹងជាសេចក្ដីសញ្ញាជាប់នៅអស់កល្ប។

យើងក៏បានឃើញថា នៅក្នុងពួកអ្នកគ្រីស្ទាន គេថ្កោលទោសព្រះដោយជ្រើសរើសយកបញ្ញត្តិណា ដែលត្រូវចិត្តរបស់គេ ហើយបដិសេធបញ្ញត្តិដែលគេមិនចូលចិត្ត តើទង្វើនេះ អ្នកគ្រីស្ទានកំពុងតែថ្កោលទោសព្រះហើយ មែនឬទេ? គឺមែន។ នៅពេលអ្នកគ្រីស្ទានថ្កោលទោសព្រះអម្ចាស់ អ្នកកំពុងតែធ្វើឲ្យខ្លួនរបស់អ្នកទទួលស្ថានភាពដ៏លំបាកបំផុតរវាងអ្នក ហើយនឹងព្រះអម្ចាស់ ពីព្រោះបើអ្នកថ្កោលទោសព្រះទៅហើយ នោះព្រះទ្រង់មិនគង់នៅជាមួយនឹងអ្នកទេ ហើយអ្នកក៏មិនអាចនៅជាមួយនឹងព្រះអង្គបានដែរ ហើយព្រះក៏ទ្រង់នឹងមិន សង្គ្រោះអស់អ្នកដែលថ្កោលទ្រង់ទេ អស់អ្នកមិនជឿព្រះបន្ទូលទ្រង់ ព្រមទាំងមិនជឿក្រិត្យវិន័យដ៏បរិសុទ្ធរបស់ព្រះ ដើម្បី

ប្រព្រឹត្តតាម ឯសេចក្តីបញ្ញត្តិក៏បរិសុទ្ធ ហើយល្អ ជារបស់ផងព្រះអម្ចាស់ទេ អ្នកកំពុងតែនិយាយថា គំនិតរបស់អ្នកល្អ ជាងព្រះ។

ឥឡូវនេះ ព្រះទ្រង់គឺជាអង្គបង្កើត របស់សព្វសារពើ ហើយល្អឥតខ្ចោះ ហេតុដូច្នេះ ហើយ គំនិតរបស់មនុស្សគ្មានជំហរទេ មនុស្សអាចជឿអ្វីៗដែលពួកគេចង់ធ្វើ ប៉ុន្តែពួកគេនឹងមិនអាចផ្លាស់ប្តូរគំនិតរបស់ព្រះ ហើយពួកគេក៏មិនអាចផ្លាស់ប្តូរថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធរបស់ព្រះបាន ហើយពួកគេក៏មិនអាចនឹងធ្វើឱ្យព្រះបាត់ទៅបានដែរ ដោយគ្រាន់តែពួកគេប្រហែលជាមានទស្សនៈមួយ ឬពីរប៉ុណ្ណោះ។

ទីបួន: យើងបានឃើញពីសេចក្តីជំនឿរបស់អ័ប្រាហាំ «ពីព្រោះអ័ប្រាហាំបានស្តាប់តាមពាក្យអញ ព្រមទាំងរក្សាបញ្ញើ នឹងបញ្ញត្តិ ហើយច្បាប់ នឹងក្រិត្យវិន័យរបស់អញ» (លោកុប្បត្តិ ២៦:៥) ហើយរួមបញ្ចូលទាំងថ្ងៃសប្ប័ទផង។

ទីប្រាំ: យើងបានឃើញនៅក្នុង អេសេគាល ជំពូក២០ ពីរបៀបដែលសាសន៍អ៊ីស្រាអែល នឹងកូនចៅរបស់ពួកគេបដិសេធថ្ងៃសប្ប័ទរបស់ព្រះ ហើយយើងបានឃើញយ៉ាងច្បាស់ថា ការបដិសេធទាំងនេះត្រូវបានប្រគល់ទៅដល់ពូជអំបូរទាំង១២ នៃសាសន៍អ៊ីស្រាអែល មិនមែនសម្រាប់តែសាសន៍យូដាទេ ហើយក៏បានក្លាយជាអំពើបាប នឹងការបះបោរ ប្រឆាំងនឹងព្រះ។ ឥឡូវនេះ សូមយើងមើលនូវយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីម្សិលមិញ ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ [ព្រះយេស៊ូវគ្រីស្ទទ្រង់ ជាព្រះនៃគម្ពីរសញ្ញា

ចាស់ដែលព្រះយេស៊ូវមានបន្ទូលៈ «ដ្បិតព្រះជាព្រះនៅក្នុងគម្ពីរសញ្ញាចាស់] ថ្ងៃនេះ [នោះជាពេលដែលប៉ុលកំពុងសរសេរសំបុត្រហេព្រើរ] ហើយទៅដល់អស់កល្បជានិច្ចតទៅជារៀងរហូត» (ហេព្រើរ ១៣:៨) ហើយមានបទគម្ពីរមួយទៀតដែលចែងថា «ដ្បិតអញ គឺយេហូវ៉ាអញមិនប្រែប្រួលឡើយ...» (ម៉ាឡាគី៣:៦) ហើយមានបទគម្ពីរមួយទៀតដែលចែងថាព្រះ «...ទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃសេចក្តីផ្លាស់ប្រែក៏គ្មានដែរ» (យ៉ាកុប១:១៧) បទគម្ពីរខាងលើនេះ បានប្រាប់យើងថាបញ្ញត្តិដប់ប្រការ នឹងថ្ងៃសប្ប័ទ នៅជាប់ស្ថិតស្ថេរនៅឡើយ ពីព្រោះបានតាំងឡើងសំរាប់មនុស្សគ្រប់គ្នា ហើយមនុស្សមាននៅលើផែនដី នៅឡើយដែរ។

ឥឡូវនេះ ចូរយើងចូលទៅកាន់គម្ពីរសញ្ញាថ្មី ហើយបន្ទាប់មក យើងនឹងត្រឡប់ទៅមើលការព្យាករណ៍មួយចំនួននៃគម្ពីរសញ្ញាថ្មី ដែលគម្ពីរសញ្ញាចាស់បានកត់ទុក។ សូមបើកទៅគម្ពីរម៉ាកុសជំពូក២ យើងបានរៀនគម្ពីរម៉ាកុសជំពូក២នេះ ពីរ បីដងពីមុនមកហើយ ប៉ុន្តែ សូមឲ្យយើងយល់យ៉ាងពិតប្រាកដនឹង យល់យ៉ាងច្បាស់លាស់ ដែលគម្ពីរនេះកំពុងបង្រៀនយើងពីព្រះបន្ទូលដ៏ជ្រាលជ្រៅ នឹងមានសកម្មបំផុត ដោយព្រោះព្រះយេស៊ូវគ្រីស្ទ ទ្រង់មានបន្ទូលថា ២២៧ «... ថ្ងៃឈប់សំរាក... [ថ្ងៃសប្ប័ទ]...បានតាំងសំរាប់ឲ្យមនុស្ស ...[ភាសាក្រិកមានន័យថា ដោយ

សារមនុស្ស...មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ ក្នុងពាក្យផ្សេងទៀត ដោយសារតែមនុស្សត្រូវបានបង្កើតឡើង ព្រះទ្រង់បានបង្កើតថ្ងៃឈប់សំរាក សំរាប់មនុស្សសំរាប់ជាផលប្រយោជន៍របស់មនុស្សសំរាប់ការសំរាករបស់មនុស្ស ហើយនឹងសំរាប់ការប្រកបជាមួយនឹងព្រះ ដែលបានបង្កើតមនុស្សមក។ ដូចដែលយើងបានរៀបរាប់ពី ថ្ងៃឈប់សំរាក គឺជាថ្ងៃបរិសុទ្ធ ដ៏អស្ចារ្យ នៅថ្ងៃសប្ប័ទដំបូងមានអ័ដាម អេវ៉ា ហើយនឹងព្រះប្រកបជាមួយគ្នា ភ្លាមៗបន្ទាប់ពីពួកគេត្រូវបានបង្កើតឡើង ហើយព្រះអម្ចាស់ទ្រង់ក៏មានព្រះបន្ទូលជាមួយគេ ហើយបង្រៀនពួកគេនៅថ្ងៃសប្ប័ទនោះ ហើយព្រះអម្ចាស់ទ្រង់ក៏ចង់ធ្វើការជាមួយនឹងយើងរាល់គ្នានៅថ្ងៃនេះ តាមរយៈវិញ្ញាណបរិសុទ្ធរបស់ទ្រង់ តាមរយៈព្រះបន្ទូលរបស់ទ្រង់ ហើយតាមរយៈអ្នកបំរើរបស់ទ្រង់ ដើម្បីឲ្យយើងទាំងអស់គ្នា អាចប្រកបជាមួយនឹងព្រះអង្គបាន ដោយសារការប្រកបរបស់យើងរាល់គ្នាចាប់ផ្តើមពីព្រះមក។

ដូច្នេះ «ថ្ងៃសប្ប័ទត្រូវបានបង្កើតឡើងសំរាប់ប់មនុស្ស...» ថ្ងៃសប្ប័ទជាព្រះពរ ជាអត្ថប្រយោជន៍ ជាការដ៏អស្ចារ្យមកពីព្រះ «...ហើយ មិនមែនជាមនុស្សសំរាប់ថ្ងៃសប្ប័ទទេ...»នេះ មានន័យថាគ្មានអ្នកណាម្នាក់មានសិទ្ធិអំណាច ឬបុព្វសិទ្ធិ ថា «មិនចូលចិត្ត ថ្ងៃសប្ប័ទទេ ឬថា ខ្ញុំនឹងផ្លាស់ប្តូរវា ទៅថ្ងៃអាទិត្យវិញ ឬថ្ងៃច័ន្ទ ឬថ្ងៃអង្គារ ឬថ្ងៃពុធឬថ្ងៃណាក៏ដោយ មនុស្សគ្មានអំណាចលើថ្ងៃឈប់សំរាករបស់ព្រះទេ ពីព្រោះព្រះអម្ចាស់ទ្រង់បានបង្កើតថ្ងៃសប្ប័ទ។ ឥឡូវសូម

កត់ចំណាំ ១២៨ «...ដូច្នេះ... [ដោយសារតែព្រះបន្ទូលចេញពីព្រះឱស្ឋព្រះ]...កូនមនុស្ស...[ព្រះយេស៊ូវគ្រីស្ទ]... ជាម្ចាស់នៃថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]...ដែរ» ឥឡូវនេះ ថ្ងៃសប្ប័ទ ជាថ្ងៃទី៧ជាថ្ងៃបរិសុទ្ធរបស់ព្រះអម្ចាស់ (ម៉ាកុស២:២៧-២៨)។ ជាការខុសទាំងស្រុង ក្នុងការហៅថ្ងៃអាទិត្យ ជាថ្ងៃទី១ថា «ជាថ្ងៃរបស់ព្រះអម្ចាស់» លើកលែងតែអ្នកចង់ថ្វាយបង្គំព្រះក្លែងក្លាយ។

ឥឡូវនេះ អ្នកត្រូវតែយល់ថា មានព្រះគ្រីស្ទក្លែងក្លាយ បានកើតឡើងជាច្រើន។ យើងត្រូវបានគេប្រាប់ថា មិនមានព្រះឯផ្សេងទៀត នៅពីមុខយើងនោះទេ ហើយប្រសិនបើអ្នកថ្វាយបង្គំព្រះនៅថ្ងៃមួយផ្សេងទៀត នោះព្រះទ្រង់បានមានព្រះបន្ទូលថា នោះអ្នកមានព្រះមួយទៀតនៅចំពោះមុខអ្នកហើយ ឬ អ្នកកំពុងតែថ្វាយបង្គំព្រះជាឥតប្រយោជន៍ អ្នកកំពុងថ្កោលទោសព្រះអម្ចាស់ ហើយនិយាយថា «ខ្ញុំស្អប់ថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់ណាស់ ខ្ញុំមិនចូលចិត្តថ្ងៃសប្ប័ទរបស់ទ្រង់ទេ។ ឯថ្ងៃអាទិត្យ គឺវាងាយស្រួលជាង បានសំរាកសំរាប់មនុស្សគ្រប់គ្នា ហើយសូម្បីតែមេដឹកនាំសាសនា ក៏បាននិយាយថា « មែនហើយប្រសិនបើព្រះយេស៊ូវគ្រីស្ទយាងមកផែនដីនៅថ្ងៃនេះ នោះទ្រង់នឹងថ្វាយបង្គំនៅថ្ងៃអាទិត្យដែរ» ពួកគេកំពុងច្រឡំ ពួកគេកំពុងមានការភ្ញាក់ផ្អើលដ៏ធំមួយ ពីព្រោះព្រះអង្គទ្រង់ជាព្រះដែលបង្កើតថ្ងៃទី៧ ឬថ្ងៃសប្ប័ទ ទ្រង់នឹងមិនផ្លាស់ប្តូរថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទដែលទ្រង់បានបង្កើតឡើង សំរាប់មនុស្ស បន្ទាប់ពីបានបង្កើតរបស់

សព្វសារពើហើយ ដូច្នេះ នៅថ្ងៃទី៧ ព្រះអម្ចាស់ទ្រង់ក៏បង្កើតថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធសំរាប់ថ្វាយបង្គំទ្រង់ ឯថ្ងៃទី៧នោះ ហៅថាថ្ងៃសៅរ៍។

ឥឡូវនេះ ចូរយើងបើកទៅ គម្ពីរអេសាយជំពូក៥៥ ហើយបន្ទាប់មក យើងនឹងបើកបទគម្ពីរមួយចំនួនទៀត គម្ពីរអេសាយ៥៥: ៦ «ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាចនឹងរកទ្រង់ឃើញ ហើយអំពាវនាវដល់ទ្រង់ ក្នុងកាលដែលទ្រង់គង់នៅជិតចុះ» ដើម្បីស្វែងរកព្រះយេហូវ៉ា មនុស្សត្រូវស្ដាប់បង្គាប់ព្រះអង្គ រក្សាថ្ងៃសប្ប័ទ ដើម្បីញែកចេញជាបរិសុទ្ធ។ ទស្សនៈវិទូ នៃគ្រិស្ដសាសនា គ្រូគង្វាល គ្រូបង្រៀនព្រះគម្ពីរ ពួកចាស់ទុំ នឹងអស់អ្នកកាន់តាមគោលលទ្ធិរបស់មនុស្ស ត្រូវបោះបង់ចោលទាំងអស់ចេញ ហើយត្រូវយល់ស្រប នឹងជឿព្រះបន្ទូលរបស់ព្រះ ហើយស្ដាប់បង្គាប់តាមព្រះបន្ទូល ហើយធ្វើតាមព្រះបន្ទូល កុំធ្វើអ្វីៗតាមតែចិត្តចង់ គឺត្រូវធ្វើតាមព្រះហឫទ័យនៃព្រះវិញ បើយើងមិនធ្វើតាមព្រះហឫទ័យរបស់ព្រះ គឺនឹងមានបញ្ហាធំជាមួយនឹងព្រះ។ យើងមិនត្រូវបង្គាប់ព្រះឲ្យធ្វើអ្វីៗ តាមចិត្តយើងចង់បាននោះទេ ដូចជាការថ្វាយបង្គំព្រះថ្ងៃអាទិត្យ ធ្វើបុណ្យណូអែល នឹងបុណ្យផ្សេងៗទៀតរបស់លោកីយនេះ។ អ្នកត្រូវតែថ្វាយបង្គំព្រះ នៅថ្ងៃសប្ប័ទ ជាថ្ងៃទី៧ ដែលព្រះទ្រង់ញែកចេញជាបរិសុទ្ធ ពីព្រោះនៅថ្ងៃទី៧នោះ មានវត្តមានព្រះដ៏បរិសុទ្ធ ទ្រង់ប្រកបជាមួយរាស្ត្ររបស់ទ្រង់ ខាងវិញ្ញាណ។

ដូច្នេះ នៅពេលអ្នកកំពុងរក្សាថ្ងៃសប្ប័ទ នោះអ្នកកំពុងតែស្វែងរកព្រះ ដូចបទគម្ពីរហេព្រើរបានចែង «តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់» (ហេព្រើរ១១:៦) ហេតុនេះ អស់អ្នកដែលចូលមកឯព្រះ ត្រូវជឿព្រះ ត្រូវជឿអ្វីៗដែលព្រះមានបន្ទូល ស្ដាប់បង្គាប់ ហើយធ្វើតាមព្រះបន្ទូល ពីព្រោះព្រះបន្ទូលទ្រង់ជាសេចក្ដីពិត ត្រូវខាងវិញ្ញាណ នឹងជីវិត។

អេសាយ៥៥ ៦. «ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាចរកទ្រង់ឃើញ ហើយអំពាវនាវ ក្នុងកាលដែលទ្រង់គង់នៅជិតចុះ ៧. ត្រូវឲ្យមនុស្សអាក្រក់បោះបង់ចោលផ្លូវរបស់ខ្លួន...[មនុស្សអាក្រក់ គឺជាមនុស្ស ដែលនិយាយថា ថ្ងៃអាទិត្យ ជាថ្ងៃសប្ប័ទ ឬជាថ្ងៃបរិសុទ្ធ]... ហើយឲ្យមនុស្សទុច្ចរិតចោលគំនិតអាក្រក់របស់ខ្លួនដែរ...» ដូច្នេះ អ្វីៗក៏ដោយដែលអ្នករាល់គ្នាមានគំនិតផ្ទុយនឹងថ្ងៃសប្ប័ទ គឺជាគំនិតទុច្ចរិត អាក្រក់ ប្រឆាំងនឹងព្រះដ៏បរិសុទ្ធ នោះអ្នកត្រូវតែបោះបង់វាចោល «...រួចឲ្យអ្នកត្រឡប់មកឯព្រះយេហូវ៉ាវិញ នោះទ្រង់នឹងអាណិតមេត្តាដល់គេ គឺឲ្យវិលមកឯព្រះនៃយើងរាល់គ្នា ដ្បិតទ្រង់នឹងអត់ទោសឲ្យជាបរិបូរ» (៦-៧)

ឥឡូវនេះ សូមមើលទៅគម្ពីរ អេសាយជំពូក៥៦ ឆ្លើយនឹងសំណួរនេះ ដែលមនុស្សតែងតែនិយាយថា ថ្ងៃសប្ប័ទ គឺសំរាប់តែ

គម្ពីរសញ្ញាចាស់ ថ្ងៃសប្ប័ទមិនមែនសំរាប់គម្ពីរសញ្ញាថ្មីទេ ថ្ងៃសប្ប័ទគឺសំរាប់តែជនជាតិយូដា ថ្ងៃសប្ប័ទមិនមែនសំរាប់យើង ជាសាសន៍ដទៃទេ នេះជាការយល់មិនស្របតាមបទព្រះគម្ពីរទេ។

ឥឡូវសូមយើងមើលបទគម្ពីរខ្លះ ដែលទាក់ទងនឹងថ្ងៃសប្ប័ទ គម្ពីរអេសាយ៥៦ ១១. «ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូររក្សាសេចក្តីយុត្តិធម៌ ហើយប្រព្រឹត្តតាមសេចក្តីសុចរិតចុះ ពីព្រោះសេចក្តីសង្គ្រោះរបស់អញបានជិតមកដល់ហើយ...យើងត្រូវយល់ព្រះយេស៊ូវគ្រីស្ទទ្រង់ជិតយាងមកវិញហើយ ... តើជិតដល់ត្រឹមណា? យើងមិនទាន់ដឹងទេ ប្រហែលជា៥ឆ្នាំ ឬ៦ឆ្នាំ ឬ១០ឆ្នាំទៀត ក៏មិនដឹងដែរ ប៉ុន្តែ វាយូរឆ្នាំចំពោះយើងតែចំពោះព្រះអម្ចាស់វិញ គឺមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ពីព្រោះ១ពាន់ឆ្នាំ ទុកដូចជា១ថ្ងៃ នៅចំពោះព្រះ នេះហើយហើយជាសេចក្តីទំនាយសំរាប់ជំនាន់យើងនេះវិញ... ឯសេចក្តីសុចរិតរបស់អញ ក៏រៀបនឹងសំដែងឲ្យឃើញដែរ ២២. មានពរហើយ... [មានពរអស់អ្នកកាន់ថ្ងៃសប្ប័ទ]... មនុស្សណាដែលប្រព្រឹត្តយ៉ាងនោះព្រមទាំងកូនមនុស្សណាដែលកាន់សេចក្តីនេះឲ្យខ្ជាប់ខ្ជួនផង គឺជាអ្នកដែលថែរក្សាថ្ងៃឈប់សំរាកឥតបង្អាប់ ហើយរក្សាដៃមិនឲ្យធ្វើការអាក្រក់ណាឡើយ» អ្នកនោះនឹងមានពរ ពីព្រះអម្ចាស់។ ពួកគ្រីស្ទាន [មិនមែនគ្រីស្ទាន] ឬគ្រីស្តបរិស័ទ គេគិតថា ប្រសិនបើអ្នករក្សាថ្ងៃសប្ប័ទ ឬថ្ងៃទី៧ នោះអ្នកនឹងត្រូវបណ្តាសា ប៉ុន្តែ តាមការពិត មិនមែនដូច្នោះទេ អស់អ្នកដែលរក្សាថ្ងៃសប្ប័ទ ឲ្យបានបរិសុទ្ធ នោះគឺជាអ្នក

មានព្រះពរវិញ។ សូមកត់ចំណាំ ខ៣. «ឯសាសន៍ដទៃណាដែលបានភ្ជាប់ខ្លួននឹងព្រះយេហូវ៉ាហើយ នោះមិនត្រូវឲ្យពោលថា ក្រែងព្រះយេហូវ៉ាទ្រង់នឹងញែកខ្ញុំចេញពីរាស្ត្រទ្រង់ទៅ» ពីព្រោះព្រះយេហូវ៉ា ទ្រង់មិនបោះបង់ចោលអស់អ្នកដែលបានកាន់ខ្ជាប់ខ្លួនតាមថ្ងៃបរិសុទ្ធរបស់ទ្រង់ទេ។

សព្វថ្ងៃនេះ ពួកជំនុំនៃព្រះ គឺជារាស្ត្ររបស់ព្រះ។ បទគម្ពីរបានចែងយ៉ាងច្បាស់ថា ខ៩ «ដូច្នេះ មានសេចក្តីឈប់សំរាក...[ថ្ងៃសប្ប័ទ]...ទុកសំរាប់រាស្ត្ររបស់ព្រះនៅខាងមុខ ខ១០. ដ្បិតអ្នកណាដែលចូលទៅក្នុងសេចក្តីសំរាករបស់ទ្រង់ហើយ នោះក៏បានឈប់សំរាក ពីការខ្លួនប្រព្រឹត្តិទាំងប៉ុន្មានដូចជាព្រះបានឈប់ ពីការដែលទ្រង់ធ្វើដែរ» (ហេព្រើរ៤:៩-១០)

ព្រះអម្ចាស់ទ្រង់បានរក្សាថ្ងៃសប្ប័ទ ទុកសំរាប់រាស្ត្រទ្រង់។ អេសាយ៥៦:៣ «... នោះទ្បើយក៏មិនត្រូវឲ្យមនុស្សកំរៀរពោលថាមើលខ្ញុំនេះជាដើមឈើហួតហែងទេ នោះដែរ ខ៤. ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលពីពួកកំរៀរ ដែលរក្សាថ្ងៃសប្ប័ទ ទាំងប៉ុន្មានក៏រើសយកអ្វីៗដែលគាប់ចិត្តអញ ព្រមទាំងកាន់ខ្ជាប់តាមសេចក្តីសញ្ញារបស់អញថា... សូមយើងមើលពីលោកអ័ប្រាហាំ គម្ពីរលោកុប្បត្តិ២៦:៥ «ពីព្រោះអ័ប្រាហាំបានស្តាប់តាមពាក្យអញ ព្រមទាំងរក្សាបញ្ញើ នឹងបញ្ញត្តិ ហើយច្បាប់នឹងក្រិត្យវិន័យរបស់អញ» នេះជាព្រះបន្ទូល ជាសេចក្តីទំនាយពីពួកជំនុំសញ្ញាថ្មី របស់ព្រះអម្ចាស់ ដែលត្រូវស្តាប់តាមព្រះអង្គទាំងរក្សាបញ្ញើនឹងច្បាប់ បញ្ញត្តិ នឹងក្រិត្យវិន័យរបស់ព្រះអម្ចាស់។

សូមយើងមកឯវិហារនៃពួកជំនុំរបស់លោកីយនេះ គេមិនកាន់

ថ្ងៃសប្ប័ទទេ ដូច្នេះគេគ្មានចំណែកអ្វី ជាមួយនឹងព្រះពិតទេ ២៥. អញនឹងឲ្យមានទីកន្លែងមួយ... [ក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានសួគ៌]...នៅក្នុងវិហារអញ ហើយឲ្យមានឈ្មោះឆ្លាក់នៅជញ្ជាំងខាងក្នុង ដែលវិសេសជាងកូនប្រុសកូនស្រីទៅទៀត អញនឹងឲ្យគេមានឈ្មោះដ៏នៅអស់កល្បជានិច្ច ជាឈ្មោះដែលមិនត្រូវកាត់ចេញឡើយ» តើមានន័យយ៉ាងដូចម្តេច? នេះមានន័យថា គេនឹងទទួលបានជីវិតអស់កល្បជានិច្ច។ គម្ពីរវិវរណៈជំពូក៣ ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា ១២. អ្នកណាដែលឈ្នះ អញនឹងយកអ្នកនោះធ្វើជាសសរទ្រូងក្នុងវិហាររបស់ព្រះនៃអញ រួចអ្នកនោះនឹងមិនចេញពីទីនោះទៀតឡើយ ហើយនឹងកត់ឈ្មោះព្រះនាមនៃព្រះរបស់អញ នឹងឈ្មោះក្រុងរបស់ព្រះនៃអញ នៅលើអ្នកនោះ គឺជាក្រុងយេរូសាឡឹមថ្មី ដែលចុះពីស្ថានសួគ៌មកអំពីព្រះនៃអញ ហើយនឹងកត់ឈ្មោះថ្មីរបស់អញដែរ» នេះជាគោលលទ្ធិសញ្ញាថ្មី ដែលហោរាអេសាយបានទាយ ប្រហែលជា៨០០ឆ្នាំមុន សញ្ញាថ្មី ត្រូវបានអនុម័ត។

អេសាយ៥៦:៦ «ឯពួកសាសន៍ដទៃ ដែលខ្ជាប់ខ្ជួននឹងព្រះយេហូវ៉ា ដើម្បីធ្វើការងារទ្រង់ ហើយនឹងស្រឡាញ់ព្រះនាមនៃព្រះយេហូវ៉ា ព្រមទាំងធ្វើជាអ្នកបំរើទ្រង់ គឺអស់អ្នកណាដែលរក្សាថ្ងៃឈប់សំរាកឥតបង្អាប់ឡើយ ហើយកាន់ជាប់តាមសេចក្តីសញ្ញារបស់អញ... [នេះជាសេចក្តីសញ្ញាថ្មី]...គ្មានសេចក្តីសង្ស័យពីថ្ងៃសប្ប័ទ នៅក្នុងបទគម្ពីរ ដែលអ្នកបំរើព្រះត្រូវកាន់ឲ្យបានខ្ជាប់ខ្ជួន ហេតុនេះហើយបានជាអ្នកបំរើព្រះត្រូវរក្សាថ្ងៃសប្ប័ទ កុំឲ្យសៅហ្មង ពីព្រោះព្រះទ្រង់បញ្ជាឲ្យរក្សាឲ្យបាន

បរិសុទ្ធ ៧. នោះអញនឹងនាំគេមកឯភ្នំបរិសុទ្ធរបស់អញ...[ភ្នំ គឺក្រុងយេរូសាឡឹមថ្មី]...ហើយឲ្យគេបានអរសប្បាយនៅក្នុងដំណាក់របស់អញ ដែលសំរាប់ជាទីអធិស្ឋាន អញនឹងទទួលអស់ទាំងដង្វាយដុត នឹងយញ្ញបូជារបស់គេ នៅលើអាសនា ដ្បិតដំណាក់អញនឹងបានហៅជាទីអធិស្ឋានសំរាប់គ្រប់ទាំងសាសន៍» (៦-៧) នោះហើយជាមូលហេតុ ដែលព្រះយេស៊ូវយាងទៅក្រុងយេរូសាឡឹម លោកយ៉ូហាន បានសរសេរ យ៉ូហាន២:១៤-១៥ «រីឯបុណ្យរំលងរបស់សាសន៍យូដា ក៏ជិតមកដល់ នោះព្រះយេស៊ូវ ទ្រង់យាងឡើងទៅក្រុងយេរូសាឡឹម ១៤. កាលទ្រង់ឃើញពួកអ្នកលក់គោ លក់ចៀម លក់ព្រាប នឹងពួកអ្នកដូរប្រាក់អង្គុយនៅក្នុងព្រះវិហារ ១៥. នោះទ្រង់ក៏យកខ្សែធ្វើជារំពាត់ដេញគេចេញពីព្រះវិហារទាំងអស់ទៅ គឺចេញទាំងចៀម ទាំងគោ ហើយក៏ចាក់ប្រាក់របស់ពួកអ្នកដូរចេញដែរ ព្រមទាំងផ្កាប់តុគេផង» (១៤-១៥) ម៉ាកុស ១១:១៧ «ដំណាក់របស់អញ នឹងបានហៅជាទីអធិស្ឋានសំរាប់គ្រប់ទាំងសាសន៍»

ឥឡូវនេះ ចូរយើងបើកទៅគម្ពីរអេសាយ៥៨:១៣ «បើឯងឃាត់ជើងឯង មិនឲ្យបែរចេញពីថ្ងៃឈប់សំរាក គឺមិនឲ្យធ្វើតាមអំពើចិត្តនៅថ្ងៃបរិសុទ្ធរបស់អញ បើឯងរាប់ថ្ងៃឈប់សំរាកទុកជាទីរីករាយចិត្ត ហើយលើកថ្ងៃបរិសុទ្ធរបស់ព្រះយេហូវ៉ា ទុកជាថ្ងៃគួរគោរព ព្រមទាំងប្រតិបត្តិតាមផង ឥតធ្វើតាមអំពើចិត្តរបស់ខ្លួន...[តើមានអ្នកណាប្រកាសថាថ្ងៃសប្ប័ទ មិនបរិសុទ្ធ មិនល្អសំរាប់គ្រីស្ទាន? តើអ្នកណា

មានអំណាចបដិសេធថ្ងៃបរិសុទ្ធរបស់ព្រះ ដែលទ្រង់បង្កើត ថាជាថ្ងៃមិនគួរកាន់តាម? តើអ្នកណាមានអំណាចធំជាងព្រះ ដែលផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅជាថ្ងៃអាទិត្យ... ឬស្វែងរកសេចក្តីអំណរដល់ខ្លួនឯង... [ថ្ងៃសប្ប័ទ ជាអំណរ មិនមែនជាបន្ទុកទេ]... ឬពោលតែពាក្យរបស់ផង់ខ្លួនឡើយ» ឬមានគំនិតផ្ទាល់ខ្លួនណា ឬលេងកីឡាផ្សេងៗ ដែលកីឡាទាំងអស់នោះ តែងតែលេងនៅថ្ងៃសៅរ៍ៗ នៅថ្ងៃសប្ប័ទរបស់ព្រះ យើងត្រូវសិក្សាព្រះបន្ទូលរបស់ព្រះ យើងត្រូវធ្វើទីបន្ទាល់ពីព្រះអង្គ យើងត្រូវរៀនឲ្យស្គាល់ផ្លូវពិតរបស់ព្រះ ដើម្បីប្រព្រឹត្តិតាមៗ

ឥឡូវនេះ អ្នកឃើញទេ សាតាំងបានត្រួតត្រាពិភពលោកនេះ តាមរបៀបដែលវាបានរៀបចំព្រឹត្តិការណ៍សំខាន់ៗ ជាច្រើននៅថ្ងៃសៅរ៍ នៅពេលដែលមនុស្សអង្គុយចុះ នឹងមានគំនិតខាងសាច់ឈាម ដើម្បីជ្រើសរើសអ្វីដែលពួកគេចង់បាន គេនឹងរើសយកផ្លូវខាងសាច់ឈាមរបស់ពួកគេទេ ពីព្រោះវិធីខាងសាច់ឈាមមានភាពទាក់ទាញចិត្តគេៗ ពួកលក់សំបុត្រសំរាប់កីឡាគ្រប់ប្រភេទ គេលក់ដាច់បំផុតនៅអស់ទាំងថ្ងៃសៅរ៍ ហើយពួកគេមាន កីឡាគ្រប់ប្រភេទ នៅថ្ងៃសៅរ៍ អ្នកឃើញហើយ នោះគឺជាតណ្ហារបស់ពិភពលោក នឹងមោទនភាពនៃជីវិត នោះមិនមែនមកពីព្រះទេៗ នេះជាអ្វីដែលមកអំពីព្រះ

១៤. «គ្រានោះឯងនឹងបានចិត្តរីករាយក្នុងព្រះយេហូវ៉ា ហើយអញនឹងបញ្ជិះឯងនៅលើទីខ្ពស់នៃផែនដី...» (អេសាយ៥៨:១៣-១៤)

ដូច្នេះ អ្នកនឹងមានចិត្តសប្បាយនឹងព្រះអម្ចាស់ ពីព្រោះអ្នកបាន

ចាប់ផ្តើមកាន់ថ្ងៃសប្ប័ទ «...ហើយអញនឹងបញ្ជិះឯងនៅលើទីខ្ពស់នៃផែនដី...» នេះកំពុងតែនិយាយអំពីមរតកនៃសេចក្តីសញ្ញាថ្មី គឺជាកូនប្រុស កូនស្រីរបស់ព្រះអម្ចាស់ «...ហើយនឹងចិញ្ចឹមឯងដោយមរដករបស់យ៉ាកុប ជាឰយុកោឯង ដ្បិតព្រះឱស្ឋនៃព្រះយេហូវ៉ាបានចេញវាចាហើយ» ដូច្នេះ ពេលណាដែលព្រះអម្ចាស់មានបន្ទូលហើយ ចូរដឹងថា ការនោះនឹងកើតឡើង។

ឥឡូវនេះ ចូរយើងបើកទៅគម្ពីរសញ្ញាថ្មី សូមលើកយកចំណុចមួយចំនួនទៀតមកសិក្សា ឲ្យបានយល់ រួចដាក់បញ្ចូលគ្នាដើម្បីវិភាគ។ ចូរយើងបើកទៅ គម្ពីរម៉ាថាយជំពូក៥ សូមមស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅ ពីព្រោះអ្នកគ្រីស្ទានភាគច្រើន គិតថា គេនៅក្រោមគម្ពីរសញ្ញាថ្មី គេមិនចាំបាច់រក្សាច្បាប់ បញ្ញត្តិណាមួយឡើយ ព្រោះព្រះគ្រីស្ទបានចំពេញតាមច្បាប់គម្ពីរសញ្ញាចាស់រួចស្រេចហើយ។ សូមស្តាប់ព្រះបន្ទូលរបស់របស់ព្រះគ្រីស្ទ គម្ពីរម៉ាថាយ ៥:១៧ «កុំឲ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យវិន័យ ឬទំនាយពួកហោរាចោលឡើយ...»តើយើងបានអានអ្វីនៅគម្ពីរអេសាយ? យើងបានអានទំនាយនៃការរក្សាសេចក្តីសញ្ញាថ្មីនៃថ្ងៃសប្ប័ទ តើមែនទេ? បាទ ពិតមែនហើយ! «ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹងធ្វើឲ្យសំរេចវិញ» តែឥឡូវនេះ ព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ បានសម្រេច តាមទំនាយទាំងអស់អំពីអង្គទ្រង់ ហើយបន្ទាប់មក ទ្រង់បានធ្វើបុណ្យរំលង ដោយថ្វាយអង្គទ្រង់ ជំនួស

យញ្ញបូជារបស់សត្វ ដោយព្រះយេស៊ូវគ្រីស្ទបានបំពេញតាមទំនាយនៅក្នុងព្រះគម្ពីរ។

ម៉ាថាយ៥:១៨ «ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើមួយ ឬក្បៀសមួយនៅក្នុងក្រិត្យវិន័យ ត្រូវបាត់ឡើយ ...» ក្រិត្យវិន័យទាំងអស់របស់ព្រះ នៅតែមានជាប់ជាធរមានដដែល គ្មានសំណួរអំពីថ្ងៃសប្ប័ទទេ! ថ្ងៃសប្ប័ទ គឺជាកូនសោ ដើម្បីស្គាល់ព្រះពិត។ យើងបន្ត ខ១៩ «ដូច្នេះ អ្នកណាដែលនឹងរំលងបទណាមួយសូម្បីយ៉ាងតូចបំផុតក្នុងបញ្ញត្តិទាំងនេះ ហើយបង្រៀនមនុស្សឲ្យធ្វើដូច្នោះដែរ នោះនឹងត្រូវហៅជាអ្នកតូចបំផុតក្នុងនគរស្ថានសួគ៌...» តើបញ្ញត្តិណាមួយ ដែលអ្នកគ្រីស្ទានចាត់ទុកជាតូចបំផុត? គឺជាបញ្ញត្តិទី៤ ដែលចែងថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក...» ជាថ្ងៃទី៧ ជាថ្ងៃបរិសុទ្ធរបស់ព្រះ។ វិហារកាតូលិកនៅពេលពួកគេធ្វើសេចក្តីសង្ខេបនៃបញ្ញត្តិដប់ប្រការ គេលុបបំបាត់ទាំងស្រុងនូវបញ្ញត្តិទីពីរ ដែលទាក់ទងនឹងរូបចំឡាក់ ហើយនឹងរូបព្រះ។

សូមបើកទៅគម្ពីរនិក្ខមនំជំពូក២០ ចែងពីបញ្ញត្តិទីពីររបស់ព្រះ ដែលនៅតែមានសពលភាព ប្រឆាំងនឹងពួកកាតូលិក នឹងវិហារកាតូលិកដដែល។ វិហារកាតូលិក នឹងពួកកាតូលិក គ្មានអំណាចនឹងផ្លាស់ប្តូរបញ្ញត្តិរបស់ព្រះ ហើយដឹកនាំឲ្យមនុស្សស្អប់បញ្ញត្តិរបស់ព្រះ ដោយបង្កើតថ្ងៃអាទិត្យ នឹងជ្រៀនឲ្យមនុស្សថ្វាយបង្គំព្រះ នៅថ្ងៃអាទិត្យនោះទេ។

សូមបើកទៅគម្ពីរនិក្ខមនំ២០:៤-៦ ៍៤.«កុំឲ្យឆ្លាក់រូបណាសំរាប់ឯងឲ្យសោះ ក៏កុំធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ក៏កុំក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាម នោះឡើយ...» វិហារកាតូលិក បានតាំងគ្រប់រូបសំណាកទាំងអស់ ដើម្បីគោរពប្រតិបត្តិ។ ឥឡូវនេះ សូមបើកទៅគម្ពីរម៉ាថាយ២២ ពីព្រោះជាបទគម្ពីរយ៉ាងសំខាន់ ដែលព្រះយេស៊ូវទ្រង់មានបន្ទូល ដើម្បីឲ្យយើងបានយល់ពីអត្ថន័យយ៉ាងជ្រាលជ្រៅនៃក្រិត្យវិន័យ ពីព្រោះមានមនុស្សជាច្រើន បាននិយាយថា «ខ្ញុំស្រឡាញ់ព្រះយេស៊ូវនៅតែក្នុងចិត្តខ្ញុំ» ហើយអ្វីៗដែលខ្ញុំធ្វើសំរាប់តែស្រឡាញ់ព្រះប៉ុណ្ណោះ។ តើអ្នកស្រឡាញ់ព្រះ ហើយបដិសេធបញ្ញត្តិរបស់ព្រះឬ? តើអ្នកបែរខ្នងដាក់បញ្ញត្តិរបស់ព្រះដោយបដិសេធថ្ងៃសប្ប័ទ ដើម្បីរក្សាថ្ងៃអាទិត្យឬ? ហើយអ្នកធ្វើបុណ្យណូអែល ឬបុណ្យគ្រីស្មាស ធ្វើបុណ្យអេស្ទើរ បុណ្យទាំងអស់នេះ ជាបុណ្យរបស់លោកីយ មិនមានចែងទុកនៅក្នុងព្រះគម្ពីរបរិសុទ្ធទេ ហើយព្រះអម្ចាស់ទ្រង់ក៏មិនដែលបង្គាប់ឲ្យយើងធ្វើបុណ្យទាំអស់នោះដែរ។

សូមយើងបើកគម្ពីរម៉ាថាយ២២:៣៧-៤០ តើសេចក្តីស្រឡាញ់របស់ព្រះជាអ្វី? យើងនឹងអានបទគម្ពីរមួយចំនួនទៀតនៅក្នុង គម្ពីរម៉ាថាយ ហើយបន្ទាប់មកយើងនឹងបើកទៅសំបុត្រទី១ របស់សាវកយ៉ូហាន ម៉ាថាយ២២: ៍៣៧.«នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រ

ឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយ អស់អំពីគំនិតឯង» ដូច្នេះ ផ្លូវរបស់ព្រះជាផ្លូវនៃជីវិត នៅពេញពេល មិនមែនធ្វើតែនៅថ្ងៃសប្ប័ទ ឬធ្វើក្នុងមួយសប្តាហ៍ម្តងនោះទេ ទោះជានៅកន្លែងធ្វើការ យើងក៏អាចធ្វើការយោងតាមបញ្ញត្តិរបស់ព្រះបាន ដោយធ្វើការឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតរបស់យើង ពីព្រោះព្រះទ្រង់ប្រទានឲ្យយើងមានជីវិត មានខ្យល់ដង្ហើម គឺព្រះដែលទ្រង់ប្រទានចិត្ត ប្រទានព្រលឹង ប្រទានគំនិត ដល់យើង ហេតុដូច្នេះហើយ បានជាព្រះអម្ចាស់ទ្រង់ទាមទារឲ្យយើងរាល់គ្នា ប្រព្រឹត្តតាមបញ្ញត្តិរបស់ព្រះអង្គ ដោយមានបន្ទូលថា «នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១ ហើយបញ្ញត្តិទី២ ក៏បែបដូចគ្នា គឺថា ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង» សូមកត់ចំណាំៈ ខ៤០. នេះជាខគម្ពីរមួយយ៉ាងសំខាន់ បើអ្នកស្រឡាញ់ព្រះ អ្នកត្រូវតែប្រព្រឹត្តតាមបញ្ញត្តិ ពីព្រោះ «បណ្តាក្រិត្យវិន័យ នឹងអស់ទាំងទំនាយហោរា ទាំងប៉ុន្មាន ក៏សំរេចនៅបទបញ្ញត្តិទាំង២ប្រការនេះឯង» (ខ៣៧-៤០) នេះជាខគម្ពីរ ដ៏មានន័យយ៉ាងជ្រាលជ្រៅ ចំពោះអស់អ្នកដែលស្រឡាញ់ព្រះៗ ព្រះបន្ទូលរបស់ព្រះអង្គ មានន័យដូចដែលព្រះទ្រង់មានបន្ទូល សូមយើងបើកទៅគម្ពីរម៉ាថាយ១៩:១៦. «នោះមានម្នាក់មកទូលទ្រង់ថា លោកគ្រូល្អអើយ តើត្រូវឲ្យខ្ញុំធ្វើការល្អអ្វីឲ្យបានជីវិតរស់នៅ អស់កល្បជានិច្ច? ខ១៧. ព្រះយេស៊ូវមានបន្ទូលថា «...អ្នកចង់ចូលទៅក្នុងជីវិត ចូរកាន់តាមបញ្ញត្តិទាំងប៉ុន្មានចុះ» នៅក្នុងបញ្ញត្តិ

នោះ មានការរក្សាថ្ងៃសប្ប័ទ ឲ្យបានបរិសុទ្ធ ១៨. គាត់ទូលសួរថា តើបញ្ញត្តិណាខ្លះ? នោះព្រះយេស៊ូវមានបន្ទូលថា កុំឲ្យសំឡាប់មនុស្ស ឲ្យសោះ កុំឲ្យផិតគ្នាឲ្យសោះ កុំឲ្យលួចឲ្យសោះ កុំឲ្យធ្វើទីបន្ទាល់ក្លែង ឲ្យសោះ ១៩. ចូរគោរពប្រតិបត្តិឪពុកម្តាយ ហើយចូលស្រឡាញ់ អ្នកជិតខាងខ្លួនឯង ២០. មនុស្សកំឡោះក៏ទូលទ្រង់ថា ខ្ញុំបានកាន់ តាមគ្រប់សេចក្តីទាំងនោះ តាំងពីក្មេងមកហើយ តើនៅខ្វះអ្វីទៀត? ២១. នោះទ្រង់មានបន្ទូលថា បើអ្នកចង់បានជាគ្រប់លក្ខណ៍ ចូរអ្នក ទៅលក់របស់ទ្រព្យខ្លួន ហើយចែកដល់ពួកអ្នកក្រីក្រទៅ នោះអ្នកនឹង បានទ្រព្យសម្បត្តិ នៅឯស្ថានសួគ៌វិញ រួចឲ្យមកតាមខ្ញុំចុះ ២២. កាលមនុស្សកំឡោះបានឮព្រះបន្ទូលនោះហើយ នោះក៏ចេញទៅ ទាំងព្រួយចិត្ត ព្រោះមានទ្រព្យសម្បត្តិជាច្រើន ២៣. នោះព្រះ យេស៊ូវ ទ្រង់មានបន្ទូលនឹងពួកសិស្សថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រា កដថា មនុស្សអ្នកមាននឹងចូលទៅក្នុងនគរស្ថានសួគ៌ពិបាកណាស់» (១៦-២៣) សូមរៀន អំពីកំឡោះអ្នកមាននេះ គាត់បានដាក់ជីវិត ខាងសាច់ឈាមរបស់គាត់ មុនការបំរើព្រះគ្រីស្ទ។

សូមបើកទៅសំបុត្រទី១ របស់សាវកយ៉ូហាន ជំពូក៥ ២. «កាល ណាយើងស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ នោះយើងដឹងថា ...[ព្រះអម្ចាស់ទ្រង់ចង់ដឹងថា តើយើងស្រឡាញ់ ព្រះអង្គពិត ឬទ?] ហេតុនេះ បានជាព្រះទ្រង់មានបន្ទូលថា...យើង ស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ ៣. ដ្បិតនេះហើយជាសេចក្តី

ស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់ ឯបញ្ញត្តិទ្រង់ នោះមិនមែនជាបន្ទុកដ៏ធ្ងន់ទេ» (១យ៉ូហាន៥:២-៣) កាលណាយើងស្រឡាញ់ព្រះ តើយើងត្រូវធ្វើយ៉ាងណា? គឺយើងត្រូវកាន់តាមបញ្ញត្តិរបស់ទ្រង់ៗ

សូមបើកទៅសំបុត្រទី១ របស់សាវកយ៉ូហាន២:៣-៤ ៣. «យើងរាល់គ្នាដឹងថា យើងស្គាល់ ដោយសារសេចក្តីនេះ គឺដោយសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តិរបស់ទ្រង់ ៤. អ្នកណាដែលថា បានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តិទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ» ការកាន់តាមបញ្ញត្តិ សំខាន់ណាស់ដើម្បីស្គាល់ព្រះពិតៗ យើងស្គាល់ព្រះពិត ដោយព្រោះយើងកាន់តាមបញ្ញត្តិរបស់ទ្រង់ ការកាន់តាមបញ្ញត្តិរបស់ទ្រង់ ជាប្រធានបទមួយយ៉ាងសំខាន់បំផុត ព្រះអម្ចាស់ទ្រង់មានបន្ទូលថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]...ដើម្បីញែកថ្ងៃនោះ ចេញជាបរិសុទ្ធ...» កំណត់:«អ្នកណាដែលថាស្គាល់ទ្រង់» តែរក្សាថ្ងៃអាទិត្យ គឺជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះទេៗ មានអ្នកគ្រីស្ទានជាច្រើននាក់ ថាស្គាល់ព្រះគ្រីស្ទ ប៉ុន្តែរក្សាថ្ងៃអាទិត្យ ព្រះទ្រង់ស្គាល់អ្នករក្សាថ្ងៃអាទិត្យទាំងអស់នោះឬទេ? គឺមិនស្គាល់ទេ! ជារៀងរាល់ចុងសប្តាហ៍ ពួកអ្នករក្សាថ្ងៃអាទិត្យ បានប្រព្រឹត្តរំលងបញ្ញត្តិនៃថ្ងៃសប្ប័ទជានិច្ច ពីព្រោះគេនិយាយថា ថ្ងៃអាទិត្យរបស់យើង ជាថ្ងៃបរិសុទ្ធ ពួកគ្រីស្ទានរបស់លោកីយនេះ បានតាំងខ្លួន

ឡើងខ្ពស់ជាងព្រះ។ តើអ្នកគ្រីស្ទានរបស់លោកីយនេះ គេកាន់តាមបញ្ញត្តិរបស់ព្រះឬទេ? គេមិនកាន់តាមទេ! នេះជារបៀបដែលយើងស្គាល់ទ្រង់ គឺត្រូវតែកាន់តាមបញ្ញត្តិរបស់ទ្រង់ តើបញ្ញត្តិដ៏សំខាន់របស់ទ្រង់មួយណា? «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក... [ថ្ងៃសប្ប័ទ]... ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ...»ពួកគ្រីស្ទបរិស័ទរបស់លោកីយនេះ គេថា គេស្គាល់ទ្រង់ [គេស្គាល់ព្រះយេស៊ូវ] ប៉ុន្តែគេរំលងបញ្ញត្តិរបស់ព្រះគ្រីស្ទជារៀងរាល់ថ្ងៃអាទិត្យ។ ពួកគ្រីស្ទបរិស័ទ ប្រហែលជានិយាយពីរោះ សំដីរលូន ប៉ុន្តែ គេថ្វាយបង្គំព្រះថ្ងៃអាទិត្យ តើហេតុអ្វីបានជាគេនិយាយកុហក? ពីព្រោះគេបង្រៀនថា ថ្ងៃអាទិត្យ គឺជាថ្ងៃរបស់ព្រះអម្ចាស់ គឺគេកុហក! កំណត់ចំណាំ: «អ្នកណាដែលថាបានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តិទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ» ព្រះបន្ទូលនេះមានអត្ថន័យជ្រាលជ្រៅណាស់។ មានអ្នកបំរើព្រះដែលរក្សាថ្ងៃអាទិត្យដ៏ស្មោះស្ម័គ្រមួយចំនួនគិតថា តើយើងកុហកដោយរបៀបណា? ពួកគេជាអ្នកកុហក ភូតភរ ដោយបង្រៀនថា ថ្ងៃអាទិត្យ ជាថ្ងៃរបស់ព្រះអម្ចាស់។ កំណត់ចំណាំ: ១យ៉ូហាន២:៥-៦ ៥. «តែអ្នកណាដែលកាន់តាមព្រះបន្ទូល... [ជឿព្រះបន្ទូល ប្រព្រឹត្តតាមព្រះបន្ទូល]... វិញនោះប្រាកដជាសេចក្តីស្រឡាញ់នៃព្រះបានពេញខ្នាតនៅក្នុងអ្នកនោះហើយ គឺដោយសេចក្តីនោះឯង ដែលយើងដឹងថាយើងនៅក្នុងទ្រង់ ៦. អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែ

ប្រព្រឹត្តដូចជាទ្រង់ដែរ» (១៩-៦) «ត្រូវតែប្រព្រឹត្តដូចជាទ្រង់» យើងមានកាតព្វកិច្ចប្រព្រឹត្តដូចទ្រង់ មានន័យថា យើងត្រូវថ្វាយបង្គំព្រះនៅថ្ងៃសប្ប័ទ ឬថ្ងៃទី៧ ដូចព្រះយេស៊ូវគ្រីស្ទដែរ ពីព្រោះតាមទម្លាប់ព្រះគ្រីស្ទ ទ្រង់យាងទៅសាលាប្រជុំរបស់សាសន៍យូដា នៅថ្ងៃសប្ប័ទ មិនមែនថ្ងៃអាទិត្យទេ ព្រះយេស៊ូវគ្រីស្ទ មិនដែលថ្វាយបង្គំព្រះ នៅថ្ងៃអាទិត្យទេ តើអ្នកថ្វាយបង្គំព្រះនៅថ្ងៃណា? តើអ្នកកំពុងដើរផ្លូវណា? តើអ្នករក្សាព្រះបន្ទូលរបស់ព្រះគ្រីស្ទឬទេ?

សូមបើកទៅដំណឹងល្អតាមលោកយ៉ូហាន យ៉ូហាន១៤:១៥ «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ» នេះជាព្រះបន្ទូល ដ៏មានន័យយ៉ាងជ្រាលជ្រៅ៖ តើអ្នកកាន់តាមបញ្ញត្តិព្រះឬទេ? តើអ្នករក្សាថ្ងៃសប្ប័ទរបស់ព្រះឬទេ? លោកយ៉ាកុបបានសរសេរថា «ដ្បិតអ្នកណាដែលកាន់ក្រិត្យវិន័យទាំងមូល តែភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រូវឡប់ជាមានទោសចំពោះក្រិត្យវិន័យទាំងមូលនោះហើយ» (យ៉ាកុប២:១០) អ្នកមិនមែនជាឃាតករទេ ក៏មិនមែនជាមនុស្សកំផិត ឬក៏ជាមនុស្សលួចប្លន់ កុហកទេ ប៉ុន្តែ បើអ្នកមិនរក្សាថ្ងៃសប្ប័ទ នោះអ្នកកំពុងតែកុហកខ្លួនឯង បើអ្នកជឿព្រះថ្ងៃអាទិត្យថ្វាយបង្គំព្រះថ្ងៃអាទិត្យ នោះអ្នកកំពុងប្រព្រឹត្តសេចក្តីកំផិតនឹងព្រះ ហើយអ្នកក៏គិតថា អ្នកមានគំនិតខ្ពស់ជាងព្រះ គំនិតរបស់អ្នកកំពុងតែប្រើព្រះនាមរបស់ព្រះ ជាអសារឥតការ ពីព្រោះអ្នកបានបដិសេធថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធរបស់ព្រះ ដែលព្រះទ្រង់មានបន្ទូលថា «ចូរឲ្យនឹក

ចាំពីថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]...ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨)

ដូច្នេះ អ្នកឃើញថា បើអ្នកស្រឡាញ់ទ្រង់ អ្នកនឹងកាន់តាមបញ្ញត្តិរបស់ទ្រង់ ឯបញ្ញត្តិនោះ គឺជាបញ្ញត្តិរបស់ទ្រង់ៗ ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាព្រះដែលបង្កើតរបស់សព្វសារពើ គឺទ្រង់ដែលប្រទានបញ្ញត្តិមកយើង ដើម្បីយើងបានរក្សា ហើយប្រតិបត្តិតាម សូមឲ្យយើងមើលគម្ពីរយ៉ូហាន១៤:២១. «អ្នកណាដែលមានបញ្ញត្តិរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង ខ២២. យូដា (មិនមែនអ៊ីស្ការីយ៉ុត) គាត់ទូលទ្រង់ថា ព្រះអម្ចាស់អើយ តើកើតមានហេតុដូចម្តេចបានជាទ្រង់នឹងសំដែងមកឲ្យយើងខ្ញុំស្គាល់ទ្រង់ តែមិនឲ្យលោកីយស្គាល់ផង ខ២៣. ព្រះយេស៊ូវមានបន្ទូលឆ្លើយថា បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ នោះព្រះវរបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយ<u>យើង</u>...[ព្រះវរបិតា នឹងព្រះគ្រីស្ទ]...នឹងមកឯអ្នកនោះ ក៏នឹងតាំងទីលំនៅ នៅជាមួយដែរ» (ខ២១-២៣) [...កាន់តាមពាក្យខ្ញុំ គឺកាន់តាមបញ្ញត្តិ] ឯបញ្ញត្តិនោះ ជាបញ្ញត្តិ១០ប្រការ (និក្ខមនំ២០:១-១៧, ចោទិយកថា៥:៦-២១)

យ៉ូហាន១៤:២៤ «អ្នកណាដែលមិនស្រឡាញ់ខ្ញុំ នោះមិនកាន់តាមពាក្យខ្ញុំទេ ឯពាក្យដែលអ្នករាល់គ្នាឮ នោះមិនមែនជាពាក្យខ្ញុំ គឺជា

ព្រះបន្ទូលរបស់ព្រះវរបិតា ដែលទ្រង់ឲ្យចាត់ខ្ញុំមកទេតើ» ព្រះគម្ពីរសញ្ញាចាស់ នឹងសញ្ញាថ្មី គឺជាព្រះបន្ទូរបស់ព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ដែលបណ្តាលឲ្យពួកអ្នកបំរើទ្រង់សរសេរទុកៗ តើអ្នករស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះ ឬទេ? ដូច្នេះ តាមសេចក្តីពិត បើអ្នកបដិសេធថ្ងៃសប្ប័ទ នោះអ្នកបដិសេធព្រះបន្ទូលរបស់ព្រះ គឺអ្នកបដិសេធព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទៗ ដូច្នេះ អ្នកមិនអាចនិយាយថា អ្នកស្រឡាញ់ព្រះអម្ចាស់ទេ ពីព្រោះអ្នកបានបដិសេធព្រះបន្ទូលទ្រង់ អ្នកបដិសេធថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធរបស់ព្រះអង្គហើយៗ

ឥឡូវនេះ សូមយើងបើកទៅគម្ពីរលូកា៤:១៦. «រួចទ្រង់យាងមកដល់ណាសារ៉ែត ជាស្រុកដែលទ្រង់គង់នៅពីកុមារ ក៏ចូលទៅក្នុងសាលាប្រជុំនៅថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]...តាមទំលាប់ទ្រង់ ហើយឈរឡើងដើម្បីអានមើលគម្ពីរ ១៧. គេក៏យកគម្ពីរហោរាអេសាយមកថ្វាយទ្រង់ កាលទ្រង់បានបើកគម្ពីរហើយ នោះទ្រង់រកឃើញត្រង់កន្លែងដែលមានសេចក្តីចែងទុកមកថា ១៨. វិញ្ញាណបរិសុទ្ធនៃព្រះអម្ចាស់សណ្ឋិតលើខ្ញុំ...[ព្រះគ្រីស្ទ]... ពីព្រោះទ្រង់ចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមកដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ នឹងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយឲ្យដោះមនុស្ស ដែលត្រូវគេជិះជាន់ឲ្យរួច ១៩. ព្រមទាំងប្រកាសប្រាប់ពីឆ្នាំដែលព្រះអម្ចាស់កំណត់ទុក ២០. កាលទ្រង់បានបិទគម្ពីរ ប្រគល់ដល់អ្នករក្សាសាលា

វិញហើយ នោះទ្រង់ក៏គង់ចុះ ឯពួកអ្នកដែលនៅក្នុងសាលា គេក៏សំឡឹងមើលទ្រង់ ២១. ទ្រង់ចាប់តាំងមានបន្ទូលទៅគេថា នៅថ្ងៃនេះ...[ថ្ងៃសប្ប័ទ]... បទគម្ពីរនេះបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ ២២. គ្រប់គ្នាជាសាក្សីពីទ្រង់ ក៏អស្ចារ្យក្នុងចិត្តពីព្រះបន្ទូលដ៏ផ្អែមពីរោះ ដែលចេញពីព្រះឱស្ឋទ្រង់មក ហើយគេនិយាយថា តើអ្នកនេះមិនមែនជាកូនយ៉ូសែបទេឬអី (១៦-២២) មនុស្សមិនជឿព្រះពិតទេ ក៏មិនជឿព្រះបន្ទូលនៃព្រះដែរ ពីព្រោះព្រះទ្រង់មានបន្ទូលថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ ឬថ្ងៃទី៧]...ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨) អ្នកគ្រីស្ទានរបស់លោកីយនេះ គេនឹកចាំពីថ្ងៃទី១ ឬថ្ងៃអាទិត្យវិញ។

សូមបើកទៅគម្ពីរលូកា៤:៣១-៣៦ ៣១. «ទ្រង់យាង ចុះទៅដល់កាពើណិម ជាទីក្រុងកាលីឡេ ក៏តែងតែបង្រៀនគេរាល់ថ្ងៃឈប់សំរាក...[ទ្រង់ក៏តែងតែ... ៣២. គេក៏នឹកប្លែកពីសេចក្តីដែលទ្រង់បង្រៀនណាស់ ពីព្រោះទ្រង់មានបន្ទូលដោយអំណាច ... [ព្រះបន្ទូលព្រះពេញដោយអំណាច]...៣៣. រីឯនៅក្នុងសាលានោះ មានមនុស្សម្នាក់ ដែលមានវិញ្ញាណអារក្សអសោចិ៍ចូល វាស្រែកឡើងជាខ្លាំងថា ៣៤. ហ៊ឺះ នែព្រះយេស៊ូវពីណាសារ៉ែតអើយ តើយើង...[អារក្សសាតាំង]... ហើយនឹងទ្រង់មានហេតុអ្វីនឹងគ្នា តើទ្រង់មកបំផ្លាញយើងឬអី? ខ្ញុំស្គាល់ជាក់ហើយទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ ៣៥. ព្រះយេស៊ូវក៏កំហែងវាថា ចូរស្ងៀមចុះ ហើយចេញពីមនុស្សនេះទៅ លុះអារក្សបានផ្តួលអ្នកនោះទៅកណ្តាល

ពួកគេ នោះក៏ចេញទៅឥតមានធ្វើឲ្យឈឺអ្វីឡើយ ពួកជនក៏មានការងឿងឆ្ងល់ តើពាក្យអ្វីទៅ សូម្បីអារក្សសាតាំងក៏ស្តាប់បង្គាប់ដែរ ៦៣៦. គ្រប់គ្នាក៏នឹកស្ញើចក្នុងចិត្ត ទាំងសួរគ្នាថា តើពាក្យបែបយ៉ាងណានេះ ដែលបង្គាប់ដល់វិញ្ញាណអសោចិ៍ ដោយអំណាចនឹងរិទ្ធិបាន ហើយវាក៏ចេញទៅ» (៦៣១-៣៦)

សូមបើកទៅគម្ពីរម៉ាកុសជំពូក៣ ចូរយើងសិក្សាពីព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់បានធ្វើការនៅថ្ងៃសប្ប័ទ។ អ្នកអាចសិក្សាដំណឹងល្អទាំងបួន ដែលព្រះយេស៊ូវគ្រីស្ទ បានធ្វើការនៅថ្ងៃសប្ប័ទ គម្ពីរម៉ាកុស៣:១ «ទ្រង់...[ព្រះយេស៊ូវ]... ក៏យាងចូលទៅក្នុងសាលាប្រជុំម្តងទៀត នៅទីនោះ ...ទ្រង់បង្រៀននៅគ្រប់ថ្ងៃសប្ប័ទ ទុកជាគំរូ សំរាប់ឲ្យយើងកាន់តាមគ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទទ្រង់មិនបានផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅថ្ងៃអាទិត្យទេ។ បើសិនជាព្រះយេស៊ូវទ្រង់ផ្លាស់ប្តូរ ពីថ្ងៃសប្ប័ទ ទៅថ្ងៃអាទិត្យ នោះព្រះយេស៊ូវគ្រីស្ទទ្រង់មិនមានបន្ទូលថា ទ្រង់ជាម្ចាស់នៃថ្ងៃសប្ប័ទនោះទេ...មានមនុស្សម្នាក់ស្វិតដៃម្ខាង ៦២. គេក៏ចាំមើលទ្រង់ក្រែងនឹងប្រោសឲ្យគាត់ជានៅថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]... ដើម្បីឲ្យបានរឿងចោទប្រកាន់ទ្រង់» ព្រះយេស៊ូវគ្រីស្ទបានមានព្រះបន្ទូលយ៉ាងច្បាស់ពីបញ្ញត្តិរបស់ព្រះ នៅគម្ពីរម៉ាថាយជំពូក៥, ៦, នឹង៧, អ្នកបានដឹង អ្នកបានឮនៅគម្ពីរសញ្ញាចាស់ ដែលចែងថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាកដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ...» (និក្ខមនំ២០:៨) អ្នកមិនអាចរកឃើញមានការរក្សាថ្ងៃទី១ ឬថ្ងៃអាទិត្យ នៅក្នុងបទគម្ពីរបានទេ ពីព្រោះ

ឥតមានអ្នកជឿព្រះ ឬគ្រីស្ទានណាម្នាក់រក្សាថ្ងៃទី១ ឬថ្ងៃអាទិត្យនោះទេ។ គម្ពីរម៉ាកុស៣:៣ «ទ្រង់មានបន្ទូលទៅមនុស្សស្វិតដៃថា ចូរអ្នកក្រោកឡើង ឈរនៅកណ្តាលនុះទៅ ៤. រួចទ្រង់សួរគេថានៅថ្ងៃឈប់សំរាក តើបើកឲ្យធ្វើការល្អ ឬឲ្យធ្វើការអាក្រក់ ឲ្យសង្គ្រោះជីវិត ឬឲ្យសំឡាប់បង់ ប៉ុន្តែ គេនៅតែស្ងៀម ៥. នោះទ្រង់ធាកទតទៅគេទាំងគ្នាន់ក្នាញ់ដោយមានព្រះហឫទ័យព្រួយ ព្រោះចិត្តរឹងរូស ក៏មានបន្ទូលទៅមនុស្សនោះថា ចូរលាតដៃទៅ អ្នកនោះក៏លាតហើយដៃគាត់បានជាដូចម្ខាង ៦. រួចកាលពួកផារិស៊ីបានចេញផុតទៅ នោះស្រាប់តែគេពីគ្រោះនឹងពួកហេរ៉ូឌទាស់នឹងទ្រង់ ដើម្បីរករឿងធ្វើឲ្យទ្រង់វិនាស» (១-៦) ព្រះយេស៊ូវគ្រីស្ទទ្រង់តែងតែធ្វើការល្អ នៅថ្ងៃសប្ប័ទ។ ប៉ុន្តែ ពួកផារិស៊ីដែលមានចិត្តសំអប់ព្រះយេស៊ូវ ក៏តែងតែរកកំហុសព្រះយេស៊ូវ ដើម្បីនឹងសំឡាប់ទ្រង់។

ឥឡូវនេះ សូមយើងមើលពីរបៀបថ្វាយបង្គំព្រះ ដែលព្រះយេស៊ូវមានបន្ទូល ទៅស្ត្រីសាសន៍សាម៉ារី នៅឯអណ្តូងទឹក សូមបើកទៅគម្ពីរយ៉ូហាន៤:១៩-២២ ១១៩. «ស្ត្រីនោះទូលទ្រង់ថា លោកម្ចាស់អើយ ខ្ញុំយល់ឃើញថា លោកជាហោរា ១២០. ឯពួកឰយុកោយើងខ្ញុំ បានថ្វាយបង្គំ នៅលើភ្នំនេះ...[ភ្នំកេរីស៊ីមចៅហ្វាយ៩:៧]...តែពួកលោកថា ក្រុងយេរូសាឡឹមជាកន្លែងដែលត្រូវថ្វាយបង្គំវិញ ១២១.ព្រះយេស៊ូវមានបន្ទូលថា នាងស្រីអើយ ចូរជឿខ្ញុំថា នឹងមានពេលវេលាមក ដែលអ្នករាល់គ្នានឹងមិនថ្វាយបង្គំព្រះវរបិតា នៅលើភ្នំនេះឬនៅក្រុងយេរូសាឡឹមទេ ១២២. អ្នករាល់គ្នាមិនដឹងជាខ្លួនថ្វាយបង្គំអ្វីទេ ឯយើងវិញ យើងស្គាល់ព្រះដែលយើង

ថ្វាយបង្គំ ដ្បិតសេចក្តីសង្គ្រោះកើតមកពីសាសន៍យូដា» (ខ១៩-២២)។ ស្រុកសាម៉ារី គឺនៅក្រៅស្រុកយូដា។

នេះជាខដ៏សំខាន់ គឺខ២៣ «តែនឹងមានពេលវេលាមក...[ពេលវេលាកំពុងតែមក]...ក៏នៅឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់... [ពួកអ្នកថ្វាយបង្គំព្រះពិតត្រង់ គឺពួកអ្នកថ្វាយបង្គំព្រះថ្ងៃសប្ប័ទ ហើយក៏មានពួកអ្នក ថ្វាយបង្គំព្រះខុសត្រង់ដែរ គឺពួកអ្នកថ្វាយបង្គំព្រះថ្ងៃអាទិត្យ ដោយគេកាន់តាមបញ្ញត្តិរបស់ពួកឰយុកោគេ ម៉ាកុស ៧:៩]... គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ នឹងសេចក្តីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកទាំងនោះ ឲ្យបានថ្វាយបង្គំទ្រង់នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ នឹងសេចក្តីពិតដែរ» (យ៉ូហាន៤:២៣) លោកម៉ាកុសបានសរសេរថា «...គេថ្វាយបង្គំអញ ដោយបង្រៀនសេចក្តីបញ្ញត្តិ ជារបស់មនុស្ស...» (ម៉ាកុស៧:៧) ពួកអ្នកថ្វាយបង្គំព្រះក្លែងក្លាយ គឺថ្វាយបង្គំព្រះកាន់តាមបញ្ញត្តិរបស់មនុស្ស ដូចជាការរក្សាថ្ងៃអាទិត្យ ឬថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ (អេសេគាល៨:១៤-១៦) គឺជាបញ្ញត្តិរបស់មនុស្ស។

ថ្វាយបង្គំព្រះវរបិតា ដោយវិញ្ញាណ មានន័យថា អ្នកត្រូវតែមានវិញ្ញាណបរិសុទ្ធនៃព្រះ។ ព្រះអម្ចាស់ទ្រង់នឹងមិនប្រទានវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដល់អស់អ្នកដែលមិនស្តាប់បង្គាប់ទ្រង់...» តើសេចក្តីពិតនោះជាអ្វី? ឯសេចក្តីពិតនោះ គឺជាក្រិត្យវិន័យរបស់ព្រះ (ទំនុកដំកើង ១១៩:១៤២) «...ព្រះបន្ទូលទ្រង់ជាសេចក្តីពិត» (យ៉ូហាន១៧:១៧) «បូករួមអស់ទាំងព្រះបន្ទូលនៃទ្រង់ទៅឃើញថា ពិតត្រង់ទាំងអស់ ហើយ

គ្រប់ទាំងច្បាប់ដ៏សុចរិតរបស់ទ្រង់ ក៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចដែរ» (ទំនុកដំកើង១១៩:១៦០) ព្រះអម្ចាស់ទ្រង់ស្វែងរកអស់អ្នកណាដែលថ្វាយបង្គំទ្រង់ តាមព្រះហឫទ័យទ្រង់ តាមផ្លូវដែលទ្រង់ដែលទ្រង់បានរៀបចុះទុក ឲ្យយើងត្រាប់តាម។ គម្ពីរយ៉ូហាន៤:២៤ «ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ នឹងសេចក្តីពិតដែរ» អ្នកជឿព្រះពិត ត្រូវមានកាតព្វកិច្ចថ្វាយបង្គំព្រះពិតដោយវិញ្ញាណ នឹងសេចក្តីពិត។

នៅសាម៉ារី ពួកគេថ្វាយបង្គំព្រះក្លែងក្លាយ គឺព្រះបាល។ ព្រះបាល គឺជាព្រះអាទិត្យ តើអ្នកដែលបានគិតទេ? ពួកអ្នកកាន់សាសនាក្លែងក្លាយ គេថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យ គឺថ្វាយបង្គំព្រះអាទិត្យ។ អ្នកប្រហែលជាមិនដែលបានគិតទេ!

សូមបើកទៅគម្ពីរយ៉ូហានជំពូក៥ ជាកន្លែងដែលមនុស្សនិយាយថា ព្រះយេស៊ូវបង្រៀនឲ្យមនុស្សប្រព្រឹត្តិរំលងបញ្ញត្តិរបស់ព្រះ មិនដូច្នោះទេ មិនមែនទេ! នេះជារឿងរបស់បុរសម្នាក់មានជម្ងឺ៣៨ឆ្នាំ ហើយព្រះអម្ចាស់បានចាត់ទេវតារបស់ទ្រង់មក កកូរទឹកឲ្យកំរើកឡើងនៅស្រះបេថៃសដា ក្នុងមួយឆ្នាំម្តង ដើម្បីឲ្យអ្នកណាដែលចុះទៅក្នុងទឹកបានមុនគេ នោះនឹងបានជា សូមយើងអានគម្ពីរយ៉ូហានជំពូក៥ ១៥. «នៅទីនោះមានមនុស្សម្នាក់ដែលឈឺ៣៨ឆ្នាំមកហើយ ១៦. កាលព្រះយេស៊ូវឃើញគាត់ដេកនៅ ហើយបានជ្រាបថា គាត់នៅយ៉ាងនោះ ជាយូរមកហើយ នោះទ្រង់មាន

បន្ទូលថា តើអ្នកចង់បានជាឬទេ? បុរសម្នាក់ដែលឈឺ ស្នាក់នៅស្រះបេថែសដា៣៨ឆ្នាំ គាត់ពិតជាបានស្គាល់ពួកសង្ឃ ពួកអាចារ្យផារីស៊ីជាច្រើននាក់ ប៉ុន្តែ គ្មាននរណាម្នាក់ជួយដាក់គាត់ទៅក្នុងទឹកពេលទឹកកំរើកឡើងនោះទេ ៥៧. អ្នកជំងឺទូលឆ្លើយថា លោកម្ចាស់អើយ ខ្ញុំគ្មានអ្នកណានឹងដាក់ខ្ញុំទៅក្នុងស្រះ ក្នុងកាលដែលទឹកបានកំរើកឡើងនោះ ហើយកំពុងដែលខ្ញុំចុះទៅ នោះក៏មានម្នាក់ទៀត ចុះទៅមុនខ្ញុំ ៥៨. ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ចូរក្រោកឡើង យកគ្រែអ្នកដើរទៅ» តាមប្រពៃណីយ ពួកសាសន៍យូដា គេមានទំលាប់ដោយមិនអនុញ្ញាត្តិឲ្យអ្នកណាធ្វើអ្វីមួយ នៅថ្ងៃសប្ប័ទទេៗ ដូច្នេះ តើព្រះយេស៊ូវបានធ្វើការរំលងថ្ងៃសប្ប័ទឬ? «ព្រះយេស៊ូវទ្រង់មានបន្ទូលសួរពួកអ្នកប្រាជ្ញច្បាប់ នឹងពួកផារីស៊ីថា តើមានច្បាប់នឹងមើលឲ្យជា នៅថ្ងៃឈប់សំរាកឬទេ? តើព្រះបណ្តាលឲ្យមនុស្សធ្វើបាបដោយរំលងថ្ងៃសប្ប័ទឬ? សូមបើកទៅគម្ពីរយ៉ូហាន៥:៩-១៤ ៥៩. «ស្រាប់តែអ្នកនោះបានជាភ្លាម ក៏យកគ្រែដើរទៅ ឯថ្ងៃនោះ ជាថ្ងៃឈប់សំរាក ៥១០. ដូច្នេះ ពួកសាសន៍យូដា គេស្តីឲ្យអ្នកដែលបានជាថា ថ្ងៃនេះជាថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ អ្នកគ្មានច្បាប់នឹងលីគ្រែទៅទេ ៥១១. គាត់ឆ្លើយទៅគេថា លោកដែលធ្វើឲ្យខ្ញុំជា លោកបង្គាប់ថាចូរយកគ្រែឯងដើរចេញទៅ» ពួកសាសន៍យូដា ពួកអាចារ្យ នឹងពួកផារីស៊ី គេដាក់ទំនៀមទំលាប់របស់ពួយុកោគេ ពីមុនការជួយសង្គ្រោះដល់មនុស្ស ៥១២. នោះគេសួរគាត់ថា តើអ្នកណាបានប្រាប់ឲ្យអ្នក

យកគ្រែដើរទៅដូច្នេះ? ១៣. តែអ្នកដែលបានជា មិនស្គាល់ជាអ្នកណាទេ ពីព្រោះព្រះយេស៊ូវទ្រង់យាងទៅបាត់ ហើយក៏មានមនុស្សសន្ធឹកនៅទីនោះដែរ ១៤. ក្រោយនោះមក ព្រះយេស៊ូវឃើញគាត់នៅក្នុងព្រះវិហារ ក៏មានបន្ទូលទៅគាត់ថា មើល ឥឡូវអ្នកបានជាហើយ កុំឲ្យធ្វើបាបទៀត ក្រែងអ្នកកើតមានសេចក្តីអាក្រក់ជាងនេះទៅទៀត» (ខ៩-១៤) អ្នកជម្ងឺនោះ មិនបានធ្វើបាបទៀតទេ។

អ្នកជម្ងឺនោះក៏ចេញពីព្រះវិហារ ទៅប្រកាសប្រាប់ដល់ពួកសាសន៍យូដា សូមបន្តអានគម្ពីរយ៉ូហាន៥:១៥-១៧ ខ១៥. «មនុស្សនោះក៏ទៅប្រាប់ដល់ពួកសាសន៍យូដា ឲ្យដឹងថាជាព្រះយេស៊ូវ ដែលប្រោសឲ្យខ្លួនបានជា ១៦. ហេតុនោះបានជាពួកសាសន៍យូដា គេបៀតបៀនដល់ព្រះយេស៊ូវ ហើយរកសំឡាប់ទ្រង់ ដោយព្រោះទ្រង់ធ្វើការនោះនៅថ្ងៃឈប់សំរាក ឬនៅថ្ងៃសប្ប័ទ ១៧. ប៉ុន្តែព្រះយេស៊ូវមានបន្ទូលទៅគេថា ព្រះវរបិតាខ្ញុំ ទ្រង់ធ្វើការដរាបមកដល់ឥឡូវនេះ ហើយខ្ញុំក៏ធ្វើការដែរ» (ខ១៥-១៧)

នេះជាកិច្ចការ ខាងវិញ្ញាណបរិសុទ្ធ ដែលបណ្តាលឡើងឲ្យថ្វាយបង្គំព្រះអម្ចាស់នៅថ្ងៃសប្ប័ទ ដោយស្រាយចំណងដល់អស់អ្នកដែលជាប់ចំណងឲ្យរួចចេញ។

ឥឡូវនេះ ចូរយើងកត់ចំណាំ ពីចលនារបស់ពួកសាសន៍យូដា ខ១៨. «ដោយហេតុពាក្យនោះ បានជាពួកសាសន៍យូដាគេរកសំឡាប់ទ្រង់រឹតតែខ្លាំងឡើង ពីព្រោះទ្រង់មិនមែនគ្រាន់តែរំលងច្បាប់ នៃថ្ងៃ

ឈប់សំរាកតែប៉ុណ្ណោះ...ព្រះយេស៊ូវគ្រីស្ទមិនដែលរំលងបញ្ញត្តិណាមួយរបស់ទ្រង់ឡើយ។ បើព្រះយេស៊ូវគ្រីស្ទប្រព្រឹត្តរំលងបញ្ញត្តិណាមួយរបស់ព្រះ នោះព្រះយេស៊ូវគ្រីស្ទទ្រង់ មិនអាចធ្វើជាព្រះអង្គសង្គ្រោះនៃមនុស្សលោកបានឡើយ។ ព្រះយេស៊ូវគ្រីស្ទ ទ្រង់គ្មានបាបសោះ ហើយទ្រង់ក៏មិនបានប្រព្រឹត្តរំលងបញ្ញត្តិរបស់ព្រះដែរ...គឺបានទាំងហៅព្រះ ថាជាព្រះវរបិតានៃទ្រង់ថែមទៀត ហើយលើកអង្គទ្រង់ស្មើនឹងព្រះផង» ពួកសាសន៍យូដា គេមិនទទួលព្រះយេស៊ូវគ្រីស្ទ ថាជាព្រះរាជបុត្រានៃព្រះ ដែលព្រះវរបិតា ចាត់ទ្រង់ ឲ្យមកក្នុងលោកីយដើម្បីធ្វើជាព្រះអង្គសង្គ្រោះនៃមនុស្សលោកនោះទេ។ ឥឡូវនេះ សូមយើងមើលទៅឯពួកសាវក តើពួកសាវក រក្សាថ្ងៃសប្ប័ទឬទេ? សូមយើងចាប់ផ្តើមនៅគម្ពីរម៉ាថាយ២៨ គឺពីព្រះបន្ទូលបង្គាប់របស់ព្រះយេស៊ូវគ្រីស្ទដល់ពួកសាវក ខ១៨.«ឯព្រះយេស៊ូវទ្រង់ មានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំ នៅលើស្ថានសួគ៌ ហើយលើផែនដី ខ១៩. ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍... [សាសន៍ដទៃ]... ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ... [ដោយការអធិស្ឋានដាក់ដៃលើ កិច្ចការ១៩:៤-៥]...ចុះខ២០. ហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់...[ចូរឲ្យទឹកចាំពីថ្ងៃសប្ប័ទ ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ] ...មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជា

រាល់ថ្ងៃដរាបដល់បំផុតកល្ប» អាម៉ែន។ (ម៉ាថាយ២៨:១៨-២០) នេះជាព្រះបន្ទូលច្បាស់លាស់ ហើយមានខ្លឹមសារបំផុត ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់បញ្ញត្តិតាមរបស់ខ្ញុំចុះ...អ្នកណាដែលមានបញ្ញត្តិរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង» (យ៉ូហាន១៤:១៥, ២១) អ្នកគ្រីស្ទានរបស់លោកីយនេះ គេមិនស្តាប់បង្គាប់ព្រះយេស៊ូវគ្រីស្ទ ក៏មិនកាន់តាមបញ្ញត្តិរបស់ទ្រង់ដែរ។ បទគម្ពីរចែងថា «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ...[សប្ប័ទ]...ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ...រួចដល់ថ្ងៃទី៧ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ា ទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ» (និក្ខមនំ២០:៨-១១) ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា «ដូច្នេះ កូនមនុស្សជាម្ចាស់នៃថ្ងៃសប្ប័ទ» (ម៉ាកុស២:២៨)

ចូរយើងមើលទៅឯគម្ពីរកិច្ចការ ដែលចែងពីសប្ប័ទ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយបានយាងឡើងទៅស្ថានសួគ៌ ជាន់ទី៣ អស់ពេលដ៏យូរ បន្ទាប់ពីទ្រង់បានបំពេញការងារដែលព្រះវរបិតាចាត់ទ្រង់ឲ្យមកធ្វើ ហើយព្រះយេស៊ូវគ្រីស្ទក៏បានបំពេញ នឹង

ធ្វើជាគំរូ ក្នុងការរក្សាថ្ងៃសប្ប័ទយ៉ាងខ្ជាប់ខ្ជួនផងដែរ។ ព្រះយេស៊ូវទ្រង់មិនបានផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅជាថ្ងៃអាទិត្យនោះទេ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទមិនបានរក្សាថ្ងៃសប្ប័ទ សំរាប់អ្នកទេ គឺអ្នករាល់គ្នាត្រូវតែរក្សាថ្ងៃសប្ប័ទឲ្យបានខ្ជាប់ខ្ជួន ដោយខ្លួនឯង។ យើងរាល់គ្នាត្រូវតែរក្សាថ្ងៃសប្ប័ទ ពីព្រោះជាថ្ងៃបរិសុទ្ធរបស់ព្រះ ដែលយើងត្រូវតែរក្សាឲ្យបានបរិសុទ្ធ។

សូមបើកទៅគម្ពីរកិច្ចការ១៦ ពេលសាវកប៉ុលទៅស្រុកក្រិក លោកក៏ទៅឯពួកយូដា នឹងពួកសាសន៍ដទៃ ដែលនៅស្រុកក្រិក ខ១៣.«ដល់ថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]... យើងដើរចេញពីទីក្រុងទៅឯមាត់ទន្លេ ជាកន្លែងដែលគេធ្លាប់អធិស្ឋាន ក៏អង្គុយនិយាយនឹងពួកស្រីៗ ដែលប្រជុំគ្នា ខ១៤. នោះមានស្ត្រីម្នាក់ជាអ្នកជំនួញលក់ពណ៌ស្វាយឈ្មោះលីឌា ពីក្រុងធាទេរ៉ា ជាអ្នកដែលថ្វាយបង្គំព្រះ នាងប្រុងស្តាប់ហើយព្រះអម្ចាស់ទ្រង់បើកចិត្តនាង ឲ្យយកចិត្តទុកដាក់តាមសេចក្តី ដែលប៉ុលអធិប្បាយ ខ១៥. កាលនាងបានទទួលបុណ្យជ្រមុជទឹក ព្រមទាំងពួកគ្រួនាងរួចហើយ នោះក៏អញ្ជើញយើងថា បើអស់លោកយល់ឃើញថា ខ្ញុំស្មោះត្រង់ចំពោះព្រះអម្ចាស់ពិតនោះ សូមលោកអញ្ជើញទៅនៅឯផ្ទះខ្ញុំកុំខាន នាងក៏បង្ខំដល់យើង» (ខ១៣-១៥)

ថ្ងៃសប្ប័ទ ជាថ្ងៃដ៏សំខាន់ណាស់ យើងឃើញមនុស្សជាច្រើនបានប្រែចិត្តជឿដល់ព្រះអម្ចាស់ នៅថ្ងៃសប្ប័ទ ដោយសេចក្តី

អធិប្បាយរបស់សាវកប៉ុល។ ឥឡូវនេះ សូមយើងបើកទៅគម្ពីរកិច្ចការជំពូក១៧ យើងរៀនពីដំណើររបស់សាវកប៉ុលដែលលោកចុះទៅដល់ទីក្រុងថែស្សាឡូនីច នេះជាចំណុចដ៏សំខាន់សំរាប់ឲ្យយើងយល់ ១១. «កាលបានដើរកាត់ក្រុងអាំភីប៉ូលី នឹងក្រុងអ័ប៉ុឡូនា នោះគេទៅដល់ក្រុងថែស្សាឡូនីច ជាកន្លែងដែលមានសាលាប្រជុំរបស់សាសន៍យូដា ១២. ប៉ុលក៏ចូលទៅឯគេតាមទំលាប់គាត់ ហើយជជែកពន្យល់ដល់គេតាមគម្ពីរ ក្នុង៣ថ្ងៃឈប់សំរាក ១៣. ក៏បើកសំដែងយ៉ាងច្បាស់ថាព្រះគ្រីស្ទត្រូវតែរងទុក្ខ រួចមានព្រះជន្មរស់ពីស្លាប់ឡើងវិញ គាត់ក៏និយាយថា ព្រះយេស៊ូវនេះឯង ដែលខ្ញុំប្រកាសប្រាប់ដល់អ្នករាល់គ្នា ទ្រង់ជាព្រះគ្រីស្ទនោះហើយ» (កិច្ចការ១៧: ១-៣) ក្នុងរវាង៣ថ្ងៃឈប់សំរាក [ថ្ងៃសប្ប័ទ] សាវកប៉ុលបានពន្យល់យ៉ាងច្បាស់អំពីព្រះយេស៊ូវ នឹងថ្ងៃសប្ប័ទ ដល់ពួកសាសន៍យូដា នឹងពួកសាសន៍ដទៃ ជាថ្ងៃបរិសុទ្ធ របស់ព្រះ ដែលត្រូវថ្វាយបង្គំទ្រង់។ សូមយើងបើកទៅគម្ពីរកិច្ចការជំពូក១៨ យើងឃើញសាវកប៉ុលបានរក្សាថ្ងៃឈប់សំរាក...[ថ្ងៃសប្ប័ទ]... ជាថ្ងៃបរិសុទ្ធ ១៤. គាត់ក៏អធិប្បាយនោះក្នុងសាលា បជុំរាល់តែថ្ងៃឈប់សំរាក ព្រមទាំងបញ្ចុះបញ្ចូលពួកសាសន៍យូដា នឹងសាសន៍គ្រេក ឲ្យជឿផង ... សាវកប៉ុលបានរក្សាថ្ងៃសប្ប័ទ ហើយក៏បញ្ចុះបញ្ចូលពួកសាសន៍យូដា នឹងពួកសាសន៍ដទៃ ឲ្យជឿផង...១៥, សាវកប៉ុលមានសេចក្តីបង្ខិតក្នុងចិត្ត ឲ្យផ្សាយព្រះបន្ទូល ក៏ធ្វើបន្ទាល់អស់អំពីចិត្តដល់សាសន៍

យូដាថា ព្រះយេស៊ូវជាព្រះគ្រីស្ទពិត ៦. តែដោយព្រោះគេតាំងខ្លួនទាស់ទទឹង ហើយក៏ជេរប្រមាថផង ប៉ុលរលាស់អាវខ្លួននិយាយថា ចូរឲ្យឈាមអ្នករាល់គ្នាធ្លាក់លើក្បាលអ្នករាល់គ្នាវិញចុះ ឯខ្ញុំៗ...[ប៉ុល]...បរិសុទ្ធទេ អំណឹះទៅមុខ ខ្ញុំនឹងទៅឯសាសន៍ដទៃហើយ ៧. គាត់ក៏ចេញពីទីនោះ ចូលទៅក្នុងផ្ទះម្នាក់ ឈ្មោះយូស្ទុស ជាអ្នកថ្វាយបង្គំព្រះ ថ្ងៃសប្ប័ទដែលមានផ្ទះនៅជាប់នឹងសាលាប្រជុំ ៨. ឯគ្រីសប៉ុស ជាមេសាលាប្រជុំគាត់ជឿដល់ព្រះអម្ចាស់ ព្រមទាំងពួកគ្រួគាត់ទាំងអស់ដែរ ក៏មានពួកក្រុងកូរិនថូសបានស្ដាប់ ហើយជឿជាច្រើនទាំងទទួលបុណ្យជ្រមុជទឹកផង ៩. វេលាយប់នោះ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅប៉ុលក្នុងការជាក់ស្ដែងថា កុំឲ្យខ្លាចអ្វី ចូរសំដែងទៅ កុំនៅស្ងៀមឡើយ ១០. ដ្បិតខ្ញុំ...[ព្រះគ្រីស្ទ]... នៅជាមួយនឹងអ្នកហើយ គ្មានអ្នកណានឹងប្រទូស្តដល់អ្នកបានទេ ខ្ញុំ...[ព្រះគ្រីស្ទ]... ក៏មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះដែរ ១១. គាត់ប៉ុលក៏នៅទីនោះអស់ ១ឆ្នាំ៦ខែ ព្រមទាំងបង្រៀនព្រះបន្ទូលនៅក្នុងពួកគេ» (៦-១១) សាវកប៉ុលបានរក្សាថ្ងៃសប្ប័ទ ថ្វាយបង្គំព្រះនៅថ្ងៃសប្ប័ទ បង្រៀនព្រះបន្ទូលនៅថ្ងៃសប្ប័ទ អស់១ឆ្នាំ ៦ខែ នៅក្រុងកូរិនថូស។

សូមយើងមើលទៅគម្ពីរកិច្ចការជំពូក១៣. ជាគម្ពីរមួយដែលជាឱកាសដ៏ល្អដល់ពួកសាវក ដូចជាសាវកប៉ុលជាដើម ១៤. «តែគេចេញពីពើកា ដើរកាត់ទៅឯអាន់ទីយ៉ូក នៅស្រុកពីស៊ីឌា ក៏ចូលទៅអង្គុយក្នុងសាលាប្រជុំ នៅថ្ងៃឈប់សំរាក ១៥. ក្រោយការដែលអានមើលក្រិត្យវិន័យ នឹងគម្ពីរពួកហោរាហើយ នោះមេសាលាក៏ប្រើ

មនុស្ស ឲ្យប្រាប់គេថា បងប្អូនអើយ បើមានសេចក្តីអ្វីនឹងទូន្មានដល់ពួកជន នោះសូមបងប្អូនមានប្រសាសន៍ចុះ» (កិច្ចការ១៣:១៤-១៥) សាវកប៉ុល ក្រោកឈរឡើង ហើយអធិប្បាយព្រះបន្ទូលព្រះដ៏មានអំណាច សាវកប៉ុលក៏អធិប្បាយព្រះបន្ទូលថា ខ៣៩. «...ដោយសារទ្រង់ អស់អ្នកណាដែលជឿ បានរាប់ជាសុចរិត រួចពីគ្រប់ការទាំងអស់ ដែលពុំអាចនឹងបានរាប់ជាសុចរិត ដោយសារក្រិត្យវិន័យលោកម៉ូសេបានឡើយ» នេះមានន័យថា ក្រិត្យវិន័យដែលលោកម៉ូសេទទួល នៅភ្នំស៊ីណាយ មិនអាចជួយឲ្យយើងរួចពីបាបបានឡើយៗ សូមយើងបើកទៅគម្ពីរកិច្ចការ១៣:៣៨-៤២ ខ៣៨. «ដូច្នេះ អ្នករាល់គ្នាជាបងប្អូនអើយ សូមជ្រាបថា ដែលបានសេចក្តីប្រោសឲ្យរួចពីបាបបានប្រកាសប្រាប់ដល់អ្នករាល់គ្នា នោះគឺដោយសារព្រះអង្គ...[ព្រះគ្រីស្ទ]... នោះឯង ខ៣៩. មួយទៀត ដោយសារទ្រង់ អស់អ្នកណាដែលជឿ បានរាប់ជាសុចរិត រួចពីគ្រប់ការទាំងអស់ ដែលពុំអាចនឹងបានរាប់ជាសុចរិត ដោយសារក្រិត្យវិន័យលោកម៉ូសេបានឡើយ ខ៤០. ដូច្នេះ ត្រូវប្រយ័ត ក្រែងអ្នករាល់គ្នាកើតមានសេចក្តី ដែលពួកហោរាបានទាយទុកថា ខ៤១. នែអស់អ្នកដែលមើលងាយអើយ... យើងត្រូវតែសួរសំណួរ តើអ្នកណាជាអ្នក មើលងាយ? គឺជាពួកអ្នកដែលបង្រៀនថា ព្រះគម្ពីរសញ្ញាចាស់ មិនត្រូវប្រើទៀតទេ គឺជាពួកអ្នកដែលបង្រៀនថា ក្រិត្យវិន័យ១០ប្រការ ត្រូវបានព្យួរនៅលើឈើឆ្កាងរួចរាល់អស់ហើយ យើងមិនត្រូវកាន់តាម ឬប្រព្រឹត្តិតាមក្រិត្យ

វិន័យនោះទៀតទេ នេះជាសេចក្តីបង្រៀនក្លែងក្លាយ មិនពិតតាមព្រះបន្ទូលរបស់ព្រះទេ គឺគេបង្រៀនពីសេចក្តីរបស់មនុស្ស ខ២១.... នៃអស់អ្នកដែលងាយអើយ...តើគេមើលងាយអ្វីខ្លះ? គេមើលងាយថ្ងៃបរិសុទ្ធរបស់ព្រះ គេមើលងាយព្រះវរបិតា គេមើលងាយព្រះយេស៊ូវគ្រីស្ទ គេមើលងាយសេចក្តីសង្គ្រោះរបស់ព្រះ តាមរយៈផែនការនៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះអង្គ គេមើលងាយក្រិត្យវិន័យដ៏គ្រប់លក្ខណ៍ នឹងបរិសុទ្ធរបស់ព្រះ...ចូរភាំងឆ្ងល់ ហើយវិនាសទៅចុះ ដ្បិតអញធ្វើការមួយនៅជំនាន់ឯងរាល់គ្នា គឺជាការដែលឯងរាល់គ្នាមិនព្រមជឿឡើយ...តើការអ្វី? (អេសាយ៧:១៤.,អេសាយ៩:៦-៧) គឺនាងព្រហ្មចារី នាងប្រសូត្របានបុត្រាជាចម្បងមួយ ប៉ុន្តែ ពួកសាសន៍យូដា គេមិនជឿទេទោះ កិច្ចការ១៣:៤១...ទោះបើមានគេប្រាប់មកឯងរាល់គ្នាក៏ដោយ ខ៤២. កាលពួកសាសន៍យូដា បានចេញពីសាលាប្រជុំទៅហើយ នោះពួកសាសន៍ដទៃ ក៏សូមឲ្យប៉ុលអធិប្បាយតាមសេចក្តីទាំងនោះ នៅថ្ងៃឈប់សំរាកមួយក្រោយទៀត» (កិច្ចការ១៣:៣៨-៤២) នេះជាឱកាសដ៏ល្អសំរាប់សាវកប៉ុល បានបង្រៀនគេពីថ្ងៃឈប់សំរាកក្រោយទៀត។ នៅគម្ពីរសញ្ញាថ្មី ពួកជំនុំរបស់ព្រះអម្ចាស់ គេរក្សាថ្ងៃសប្ប័ទ ឬ ថ្ងៃទី៧ មិនមែនថ្ងៃអាទិត្យទេ ខ៤៣. កាលពួកអ្នកប្រជុំនោះបានបែកចេញពីគ្នាទៅនោះមានពួកសាសន៍យូដា នឹងពួកចូលសាសន៍ជាច្រើនដែលមកថ្វាយបង្គំគេដើរតាមប៉ុល នឹងបាណាបាស ដែលទូន្មានឲ្យគេកាន់ខ្ជាប់ក្នុង

ព្រះគុណនៃព្រះ» (ខ៤៣)

នេះជារឿងដ៏សំខាន់ ពីព្រោះមនុស្សជាច្រើននិយាយថា «ការរក្សាថ្ងៃសប្ប័ទ គឺជាច្បាប់ ប៉ុន្តែ យើងត្រីស្ពាន ថ្ងៃអាទិត្យ ស្ថិតនៅក្រោមព្រះគុណ មិននៅក្រោមច្បាប់របស់ព្រះទេ» អ្នកមិនអាចមានព្រះគុណ ដោយមិនស្ថិតនៅក្រោមច្បាប់បរិសុទ្ធរបស់ព្រះអម្ចាស់ទេ។ សូមកត់ចំណាំ ខ៤៤. ដល់ថ្ងៃឈប់សំរាកថ្ងៃសប្ប័ទ ក្រោយ នោះពួកអ្នកក្រុងស្ទើរតែទាំងអស់ ក៏មកប្រជុំគ្នា ដើម្បីនឹងស្តាប់ព្រះបន្ទូល» (កិច្ចការ១៣:៤៤)

សូមឲ្យយើងមើលមកឯគម្ពីរហេព្រើរ៤:៤-៦ ខ៤. «ដ្បិតនៅកន្លែងណាមួយទ្រង់មានបន្ទូលពីថ្ងៃទី៧ "ដូច្នេះថា ព្រះទ្រង់បានឈប់សំរាក ពីអស់ទាំងការរបស់ទ្រង់នៅថ្ងៃទី៧" ខ៥. ហើយនៅកន្លែងនេះទៀតថា «វារាល់គ្នាមិនត្រូវចូល ទៅក្នុងសេចក្តីសំរាករបស់អញសោះឡើយ» ខ៦. ដូច្នេះ ដែលនៅតែបើឲ្យអ្នកខ្លះបានចូលទៅក្នុងសេចក្តីសំរាកនោះ ហើយពួកអ្នកដែលឮដំណឹងល្អពីដើម គេមិនបានចូលទេ ដោយព្រោះមិនជឿ» (ខ៤-៦) នេះគឺជាកូនចៅសាសន៍អ៊ីស្រាអែល ដែលពួកគេមិនព្រមជឿព្រះអម្ចាស់ នៅពេលដែលពួកគេនៅវាលស្ពាន គេបានរំលងថ្ងៃសប្ប័ទ គម្ពីរនិក្ខមនំ ជំពូក ១៦ បន្ទាប់ពីព្រះទ្រង់ប្រទាននំម៉ាន៉ា នឹងសត្វគ្រួច មកឲ្យបរិភោគពួកកូនចៅសាសន៍អ៊ីស្រាអែល នៅតែរំលងបញ្ញត្តិដដែល និក្ខមនំ ១៦:១៩ «រួចម៉ូសេប្រាប់ថា កុំឲ្យអ្នកណាទុកឲ្យសល់ដល់ព្រឹកឡើយ

២០. តែគេមិនបានស្តាប់តាមទេ ក៏មានអ្នកខ្លះបានទុកនំនោះដល់ព្រឹក នោះក៏កើតមានដង្កូវ មានក្លិនស្អុយ ម៉ូសេក៏ខឹងនឹងគេ ២៧. នៅថ្ងៃទី៧ ក៏មានអ្នកខ្លះចេញទៅរើសនំនោះដែរ តែរកគ្មានសោះ» (១៩-២០, ២៧) បន្ទាប់មក លោកម៉ូសេក៏ឡើងទៅលើភ្នំ ហើយពួកកូនចៅសាសន៍អ៊ីស្រាអែលក៏សួរអើរ៉ុនថា តើលោកម៉ូសេនៅឯណា? កូនចៅអ៊ីស្រាអែល បានសូមឲ្យលោកអើរ៉ុនធ្វើព្រះសំរាប់ពួកគេ សូមបើកទៅគម្ពីរនិក្ខមនំ៣២:១-៦ ១. «កាលបណ្តាជនទាំងឡាយបានឃើញថា ម៉ូសេក្រចុះមកពីលើភ្នំវិញដូច្នេះ នោះគេប្រជុំគ្នាទៅឯអើរ៉ុន ជំរាបថា សូមលោកធ្វើព្រះសំរាប់យើងរាល់គ្នា ឲ្យបាននាំមុខយើងផង ដ្បិតឯលោកម៉ូសេ ជាអ្នកដែលនាយើងចេញពីស្រុកអេស៊ីព្ទមកនោះ យើងរាល់គ្នាមិនដឹងជាលោកមានគ្រោះថ្នាក់អ្វីទេ ២. រួចអើរ៉ុនតបទៅគេថា ដូច្នេះ ចូរដោះក្រវិលមាសពីត្រចៀកប្រពន្ធ នឹងកូនប្រុសកូនស្រីឯងរាល់គ្នាយកមកឲ្យអញ ៣. នោះគ្រប់គ្នាក៏ដោះយកទៅប្រគល់ឲ្យ ៤. ហើយលោកទទួលយកពីដៃគេទៅចាក់ក្នុងពុម្ព សិតធ្វើជារូបគោ រួចគេប្រកាសថា នែ ពួកអ៊ីស្រាអែលអើយ នេះហើយជាព្រះនៃឯង ដែលបាននាំឯង ចេញពីស្រុកអេស៊ីព្ទមក ៥. កាលអើរ៉ុបានឃើញរូបគោហើយ នោះក៏ស្អាងអាសនា១នៅមុខរូបនោះ រួចស្រែកប្រកាសថា នៅថ្ងៃស្អែកនេះនឹងមានបុណ្យថ្វាយព្រះយេហូវ៉ា ៦. លុះដល់ថ្ងៃស្អែកបណ្តាជនទាំងឡាយក៏ក្រោកឡើងពីព្រលឹម ទៅថ្វាយដង្វាយដុត នឹងដង្វាយមេត្រីក៏នាំគ្នាអង្គុយស៊ីផឹក

រួចក្រោកឡើងលេងសប្បាយ» (៦១-៦)

នៅពួកកូនចៅអ៊ីស្រាអែល ធ្វើបាប នឹងព្រះយេហូវ៉ាជានិច្ច គម្ពីរ ចៅហ្វាយជំពូក២:១០-១៣ ៦១០. «អស់ទាំងមនុស្សនៅជំណាន់នោះ ក៏បានប្រមូលទៅជួបជុំនឹងពួកឰយុកោគេគ្រប់គ្នាដែរ ហើយកើតមានមនុស្ស១ជំណាន់ទៀតក្រោយមក ជាមនុស្សដែលមិនបានស្គាល់ព្រះយេហូវ៉ា ឬការដែលទ្រង់បានសំរេចដល់ពួកអ៊ីស្រាអែល ៦១១. នោះពួកកូនចៅអ៊ីស្រាអែល ក៏ធ្វើការដ៏លាមក អាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាវិញ គឺគេគោរពប្រតិបត្តិដល់អស់ទាំងរូបនៃព្រះបាល ៦១២. គេបានបោះបង់ចោលព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទមក បែរទៅតាមព្រះដទៃ ក្នុងពួកព្រះរបស់សាសន៍ទាំងប៉ុន្មាន ដែលនៅជុំវិញគេ ព្រមទាំងក្រាបថ្វាយបង្គំដល់ព្រះទាំងនោះផង ហើយបានបណ្តាលឲ្យព្រះយេហូវ៉ាមានសេចក្តីខ្ញាល់ ៦១៣. គេបានបោះបង់ចោលព្រះយេហូវ៉ាទៅគោរពប្រតិបត្តិតាមព្រះបាល នឹងព្រះអាសថារ៉ូតវិញ» (៦១០-១៣) ការថ្វាយបង្គំព្រះបាល គឺជាការថ្វាយព្រះនៅថ្ងៃអាទិត្យ ហើយព្រះអាសថារ៉ូត ក៏ដូចគ្នាដែរ គឺជាការថ្វាយបង្គំព្រះថ្ងៃអាទិត្យដូច្នេះ ពួកកូនចៅសាសន៍អ៊ីស្រាអែល បានធ្វើបាបនឹងព្រះយេហូវ៉ាជានិច្ចៗ

សូមបើកទៅគម្ពីរទំនុកដំកើង៩៥ ជាទំនុកដំកើងរបស់លោកម៉ូសេ ទំនុកដំកើង៩៥:៧-១១ ៦៧. «ដ្បិតទ្រង់ជាព្រះនៃយើងខ្ញុំហើយ យើងខ្ញុំក៏ជាហ្វូងចៀមនៅទីគង្វាលរបស់ទ្រង់ គឺជារាស្ត្រដែលនៅក្នុង

ព្រះហស្តទ្រង់ នៅថ្ងៃនេះ...[ថ្ងៃសប្ប័ទ]...បើឯងរាល់គ្នាឮសំឡេងទ្រង់ ១៨. នោះកុំឲ្យតាំងចិត្តរឹងរូស ដូចកាលនៅត្រង់មេរីបា ឬដូចកាលថ្ងៃនៅត្រង់ម៉ាសា ក្នុងទីរហោស្ថាននោះឡើយ ១៩. នៅគ្រាដែលពួកឰយុកោឯងរាល់គ្នាបានល្បងអញ ព្រមទាំងលអញមើលហើយបានឃើញការរបស់អញ ១១០. អញមានចិត្តជិនទ្រាន់នឹងមនុស្សជំណានោះអស់ ៤០ឆ្នាំ ហើយក៏ថា នេះជាបណ្តាមនុស្សដែលតែងតែមានចិត្តវង្វេង ឥតដែលស្គាល់ផ្លូវរបស់អញឡើយ ១១១. ដូច្នេះ អញបានស្បថ ដោយសេចក្តីក្រោធរបស់អញថា វារាល់គ្នានឹងមិនដែលចូលមកក្នុងសេចក្តីសំរាក...[ថ្ងៃសប្ប័ទ]...របស់អញឡើយ» (១៧-១១) ជីតាខ្ញុំ គាត់រក្សាថ្ងៃអាទិត្យ ឪពុក ម្តាយខ្ញុំគាត់រក្សាថ្ងៃអាទិត្យ ដូច្នេះ ថ្ងៃអាទិត្យ ក៏ល្អសំរាប់ខ្ញុំដែរ គឺគ្រប់គ្រាន់ហើយ! ថ្ងៃសប្ប័ទ គឺសំរាប់តែសាសន៍យូដាទេ ថ្ងៃសប្ប័ទ មិនមែនតែសំរាប់ពួកសាសន៍យូដាប៉ុណ្ណោះទេ គឺសំរាប់ប្រជាជនរបស់ព្រះអម្ចាស់ នឹងពួកសាសន៍ដទៃដែរៗ សូមបើកទៅគម្ពីរ ១ពេត្រុស២:៩-១០ ១៩.«តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានសំដែងចេញ ឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់ ១១០. ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាទេ តែឥឡូវនេះជាសាសន៍របស់ព្រះវិញ...[យើងឃើញទំនាយនៅគម្ពីរហោរា អេសាយ ៥៦:៣ «ឯសាសន៍ដទៃណាដែលបានភ្ជាប់ខ្លួននឹងព្រះយេហូវ៉ាហើយ

នោះមិនត្រូវឲ្យពោលថា ក្រែងព្រះយេហូវ៉ាទ្រង់នឹងញែកខ្ញុំចេញពីរាស្ត្រទ្រង់ទៅ នោះឡើយ]...ពីដើមមិនបានទទួលសេចក្តីមេត្តាករុណាទេ តែឥឡូវនេះបានទទួលហើយ» (១ពេត្រុស២:៩-១០)

លោកសាវកប៉ុល បានសរសេរថា ហេព្រើរ៤:៩-១០ ខ៩. «ដូច្នេះមានសេចក្តីឈប់សំរាក... [ថ្ងៃសប្ប័ទ]... ទុកសំរាប់រាស្ត្ររបស់ព្រះនៅខាងមុខ ខ១០. ដ្បិតអ្នកណាដែលចូលទៅក្នុងសេចក្តីសំរាករបស់ទ្រង់ហើយ នោះក៏បានឈប់សំរាក ពីការខ្ជួនប្រព្រឹត្តទាំងប៉ុន្មាន ដូចជាព្រះបានឈប់ពីការដែលទ្រង់ធ្វើដែរ» (ខ៩-១០)

នេះជាព្រះបន្ទូលយ៉ាងច្បាស់លាស់ មានថ្ងៃសប្ប័ទទុកសំរាប់រាស្ត្ររបស់ព្រះ ដែលគ្មានអ្នកណាមានអំណាចអាចផ្លាស់ប្តូរថ្ងៃសប្ប័ទ ទៅជាថ្ងៃអាទិត្យ ឬទៅជាថ្ងៃណាមួយទៀត សំរាប់ថ្វាយបង្គំព្រះ នោះគ្មានទេ។

គម្ពីរយោង:

១. ហេព្រើរ១១:៦
២. ម៉ាកុស២:២៧-២៨
៣. យ៉ូហាន១:១-៣
៤. និក្ខមនំ២០:៨-១១
៥. លោកុប្បត្តិ២៦:៥
៦. អេសេគាល២០:១០-១៣

៣១. យ៉ូហាន១៤:២៤
៣២. លូកា៤:១៦-២៣
៣៣. លូកា៤:៣១-៣៦
៣៤. ម៉ាកុស៣:១-៦
៣៥. ម៉ាថាយ៥, ៦, ៧
៣៦. យ៉ូហាន៤:១៩-២២

៧. ហេព្រើរ១៣:៨

៨. ម៉ាឡាគី៣:៦

៩. យ៉ាកុប១:១៧

១០. អេសាយ៥៥:៦-៧

១១. អេសាយ៥៦:១-៤

១២. ហេព្រើរ៤:៩-១០

១៣. វិវរណៈ៣:១២

១៤. អេសាយ៥៦:៦-៧

១៥. យ៉ូហាន២:១៤-១៥

១៦. ម៉ាកុស១១:១៧

១៧. អេសាយ៥៨:១៣-១៤

១៨. ម៉ាថាយ៥:១៧-១៨

១៩. និក្ខមនំ២០:៤-៦

២០. ម៉ាថាយ២២:៣៧-៤០

២១. ម៉ាថាយ១៩:១៦-២៣

២២. ១យ៉ូហាន៥:២-៣

២៣. ១យ៉ូហាន២:៣-៤

២៤. ១យ៉ូហាន២:៥-៦

២៥. យ៉ូហាន១៤:១៥

៣៧. ចៅហ្វាយ៩:៧

៣៨. ម៉ាកុស៧:៩

៣៩. អេសេគាល៨:១៤-១៦

៤០. ទំនុកដំកើង១១៩:១៤២

៤១. យ៉ូហាន១៧:១៧

៤២. ទំនុកដំកើង១១៩:១៦០

៤៣. យ៉ូហាន៤:២៤

៤៤. យ៉ូហាន៥:៥-១៤

៤៥. យ៉ូហាន៥:១៥-១៧

៤៦. ម៉ាថាយ២៨:១៨-២០

៤៧. កិច្ចការ១៩:៤-៥

៤៨. យ៉ូហាន១៤:១៥, ២១

៤៩. កិច្ចការ១៦:១៣-១៥

៥០. កិច្ចការ១៧:១-៣

៥១. កិច្ចការ១៨:៤-១១

៥២. កិច្ចការ១៣:១៤-១៥

៥៣. កិច្ចការ១៣:៣៨-៤៤

៥៤. អេសាយ៧:១៤, ៩:៦

៥៥. ហេព្រើរ៤:៤-៦

២៦. យ៉ាកុប២:១០

២៧. និក្ខមនំ២០:៨

២៨. យ៉ូហាន១៤:២១-២៣

២៩. និក្ខមនំ២០:១-១៧

៣០. ហោទិយកថា៥:៦-២១

៥៦. និក្ខមនំ១៦:១៩-២០, ២៧

៥៧. និក្ខមនំ៣២:១-៦

៥៨. ចៅហ្វាយ២:១០-១៣

៥៩. ទំនុកដំកើង៩៥:៧-១១

៦០. ១ពេត្រុស២:៩-១០

៦១. អេសាយ៥៦:៣